ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣

រាជធានីភ្នំពេញ ខែមករា ឆ្នាំ២០១៩

# មាតិការឿង


*អារម្ភកថា*

*សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ០៣ សសរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០១៩ លើយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣*

I. សេចក្តីផ្តើម ........ 1

II. បរិការណ៍នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ........ 2

សមិទ្ធផល ........ 6

បញ្ហាប្រឈម ........ 6

កាលានុវត្តភាព ........ 6

III. គោលដៅចម្បង, ទិសដៅជាយុទ្ធសាស្ត្រ និងក្របខណ្ឌលទ្ធផល ........ 7

IV. គោលការណ៍, យន្តការ, ឧបករណ៍ និងការរៀបចំស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រ និងត្រួតពិនិត្យ ........ 10

ក- គោលការណ៍ ........ 10

ខ- យន្តការ និងឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រ និងត្រួតពិនិត្យ ........ 11

១- ការបញ្ចូលហិរញ្ញប្បទានសហប្រតិបត្តិការក្នុងថវិការដ្ឋ ........ 11

២- កិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ ........ 12

៣- ក្រុមការងារបច្ចេកទេសចម្រុះ ........ 12

៤- កិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ ........ 14

៥- កិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ........ 14

៦- កិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី-ខេត្ត ........ 15

៧- ការរៀបចំសេចក្តីណែនាំស្តីពីភាពជាដៃគូ និងការអនុវត្ត ........ 15

៨- សូចនាករតាមដានរួមគ្នា ........ 15

៩- របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ........ 16

១០- ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាល ........ 16

១១- ភាពជាដៃគូសកលសម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងការអង្កេតការប្តេជ្ញាទីក្រុងប៊ូសាន ........ 18

គ- យន្តការស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រ ........ 18

V. ភាពជាដៃគូសម្រាប់គាំទ្រលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ........ 21

១- ការកសាងភាពជាដៃគូជុំវិញការរៀបចំថវិការដ្ឋ ........ 21

២- ការគាំទ្រកម្ពុជារៀបចំខ្លួនឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ........ 22

៣- ហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ ........ 25

VI. សន្និដ្ឋាន ........ 26

# អារម្ភកថា

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តនូវយុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី ៤ ក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ។ យុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី ៤ គឺជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល ដែលគូសបញ្ជាក់អំពីរបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចកម្ពុជា សម្រាប់នីតិកាលទី ៦ របស់រដ្ឋសភា ។ យុទ្ធសាស្រ្តចតុកោណនេះនឹងត្រូវអនុវត្តតាមរយៈផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ដែលឆ្លុះបញ្ចាំងអំពីការប្តេជ្ញារបស់រាជ-រដ្ឋាភិបាលក្នុងការពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។

រាជរដ្ឋាភិបាលបានទទួលស្គាល់អំពីការរួមចំណែកនៃហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។ លើមូលដ្ឋាននេះ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.ទា) ដែលជាស្ថាប័នសម្របសម្រួលរបស់រាជរដ្ឋាភិបាល បានសម្រេចសមិទ្ធផលសំខាន់ៗជាច្រើនក្នុងការអនុវត្តយុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ ។ សមិទ្ធផលទាំងនេះរួមមាន ÷ ការពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ, ការលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការវិភាជ និងប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ និងការពង្រឹងយន្តការពិគ្រោះយោបល់កម្រិតគោលនយោបាយ ដើម្បីធានាគុណភាពនៃភាពជាដៃគូជាមួយបណ្តាតួអង្គពាក់ព័ន្ធ ។ វឌ្ឍនភាពទាំងនេះអាចសម្រេចបាន ដោយសារភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងការដឹកនាំកិច្ចអភិវឌ្ឍន៍, ភាពជាដៃគូដោយស្មើភាព និងការគោរពគ្នាទៅវិញទៅមកក្នុងកិច្ចសន្ទនាផ្នែកគោលនយោបាយជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ។

ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី ៤ ប្រកបដោយជោគជ័យ, យុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំ ដើម្បីធានាការបន្តអនុវត្ត ដោយផ្អែកលើវឌ្ឍនភាពដែលសម្រេចបានក្នុងការអនុវត្តយុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ កន្លងមក ។ គោលដៅចម្បងនៃយុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ គឺការជំរុញស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ និងផ្តោតលើលទ្ធផល ហើយត្រូវឆ្លើយតបទៅនឹងបរិការណ៍នៃការអភិវឌ្ឍកម្ពុជា ។ គោលដៅ, ទិសដៅ, គោលការណ៍, យន្តការ និងឧបករណ៍ដែលបានកំណត់ក្នុងយុទ្ធសាស្រ្តនេះ បានឆ្លុះបញ្ចាំងអំពីការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មអភិវឌ្ឍន៍សកល និងក្នុងប្រទេស ដោយបានរំលេចការប្តេជ្ញាសកលទៅក្នុងគោលការណ៍ជាតិស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។

យុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំក្នុងពេលដែលអាទិភាពក្នុងការអភិវឌ្ឍ និងបរិការណ៍របស់កម្ពុជា កំពុងវិវត្តឈានឡើង ។ លើមូលដ្ឋាននេះ ការរៀបចំយុទ្ធសាស្រ្តនេះត្រូវផ្អែកលើសក្ខីកម្ម, បទពិសោធន៍ និងទស្សនវិស័យរបស់តួអង្គអភិវឌ្ឍន៍នៅតាមបណ្តាវិស័យ ដើម្បីឈានទៅឯកភាពលើបណ្តាអាទិភាពដែលត្រូវអនុវត្តនាពេលអនាគត ។ រាជរដ្ឋាភិបាលជឿជាក់យ៉ាងមុតមាំថា ផ្អែកតាមអភិក្រមដែលបានប្រើប្រាស់សម្រាប់រៀបចំយុទ្ធសាស្រ្តនេះ គួបផ្សំជាមួយការរៀបចំក្របខណ្ឌលម្អិតសម្រាប់អនុវត្ត, យុទ្ធសាស្រ្ត

ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុម័តតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ០៣ សសរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ នឹងជួយជំរុញកម្ពុជាឈានទៅសម្រេចបាននូវគោលដៅអាទិភាពក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៤ ។

ថ្ងៃពុធ ១១ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៩

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកជា**
**អគ្គលេខាធិការ ក.អ.ក/គ.ជ.នា**

**ឈៀង យ៉ាណារ៉ា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៣ អនស

# សេចក្ដីសម្រេច
# ស្ដីពី
# យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដូចមានឯកសារភ្ជាប់នឹងសេចក្ដីសម្រេចនេះ សម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។

**ប្រការ ២.** –

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវរៀបចំសេចក្ដីណែនាំសម្រាប់អនុវត្តយន្តការ និងឧបករណ៍ ដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ ដើម្បីស្នើជូន **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ពិនិត្យ និងសម្រេច ។

**ប្រការ ៣.** –

ប្រគល់ភារកិច្ចជូនឯកឧត្ដម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសម្របសម្រួល និងតាមដានការអនុវត្ត ហើយត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ និងពាក់កណ្ដាលអាណត្តិស្ដីពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ ជូន **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ពិនិត្យ និងផ្ដល់អនុសាសន៍ ។

**ប្រការ ៤.** –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ដៃគូអភិវឌ្ឍន៍, វិស័យឯកជន, អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ↫

ថ្ងៃសុក្រ ៦ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

## I- សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ស្ថិរភាពនយោបាយ, ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយប្រយ័ត្នប្រយែង និង ដើម្បីបន្តជំរុញការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព និងបរិយាប័ន្ន, រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យអនុវត្ត នូវយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា ក្នុងកិច្ចប្រជុំពេញអង្គលើកទី ១ របស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ។ ផ្អែកលើសក្ដីកម្ម និង បទពិសោធន៍កន្លងមក, យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ដែលជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាព របស់រាជរដ្ឋាភិបាល បានរំលេចអំពីសមិទ្ធផលដ៏ត្រចះត្រចង់, កំណត់បញ្ហាប្រឈម និងកាលានុវត្តភាពនានា សម្រាប់ កម្ពុជាឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច និងសម្រេចគោលដៅប្រកបដោយមហិច្ឆតា ជាប្រទេស មានចំណូលមធ្យមកម្រិតខ្ពស់ នាឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់ នាឆ្នាំ២០៥០ ។

ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍, ភាពជាដៃគូដោយស្មើភាព និងការគោរពគ្នាទៅវិញ ទៅមកក្នុងកិច្ចសន្ទនាផ្នែកគោលនយោបាយ គឺជាគោលការណ៍ណែនាំគ្រឹះក្នុងកិច្ចសហប្រតិបត្តិការលើគ្រប់ទិដ្ឋភាព របស់កម្ពុជា ជាមួយដៃគូអភិវឌ្ឍន៍, វិស័យឯកជន និងអង្គការសង្គមស៊ីវិល ។ ផ្អែកលើគោលការណ៍ណែនាំគ្រឹះទាំង នេះ រាជរដ្ឋាភិបាលបានសម្រេចបេសកកម្មរបស់ខ្លួន ក្នុងការជំរុញកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងគ្រប់ជ្រុងជ្រោយ ។

រាជរដ្ឋាភិបាលបានប្តេជ្ញាបន្តពង្រឹងភាពជាដៃគូ ដើម្បីអនុវត្តឱ្យបានសម្រេចនូវរបៀបវារៈគោលនយោបាយ ដែល នឹងត្រូវអនុវត្តតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ រួមទាំងគោលដៅអភិវឌ្ឍន៍ប្រកបដោយ ចីរភាពកម្ពុជា ។ ក្នុងន័យនេះ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ នឹងចូលរួមយ៉ាងសកម្មក្នុង ការប្រែក្លាយការប្តេជ្ញាស្តីពីភាពជាដៃគូ ទៅជាសកម្មភាពជាក់ស្តែង តាមរយៈការដាក់ឱ្យអនុវត្តនូវគោលការណ៍, គោលដៅ, ទិសដៅ និងឧបករណ៍នានា សម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។ លើមូលដ្ឋាននេះ យុទ្ធសាស្ត្រស្តីពីកិច្ច សហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីរាជរដ្ឋាភិបាលសម្រេចគោលដៅ អភិវឌ្ឍន៍ ដោយសហការជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ។

រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តជាលើកដំបូង នូវយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជា ដៃគូ ឆ្នាំ២០១៤-២០១៨ ហើយសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើន ។ យុទ្ធសាស្ត្រនេះគឺជាក្របខណ្ឌគោល នយោបាយ សម្រាប់រាជរដ្ឋាភិបាលកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការជាមធ្យមប្រមាណជាង ១.០០០ លានដុល្លារ ក្នុងមួយឆ្នាំ សម្រាប់គាំទ្រយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ យុទ្ធសាស្ត្រ ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូបានកំណត់គោលដៅវាស់វែងមួយចំនួន សម្រាប់អនុវត្តគោលការណ៍ ស្តីពីគណនេយ្យភាពទ្វេទិស ក្នុងទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្របាន កំណត់ឧបករណ៍ និងអភិក្រមមួយចំនួន សម្រាប់ជំរុញកិច្ចសហការរវាងរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍, អង្គការសង្គម ស៊ីវិល, វិស័យឯកជន និងប្រតិបត្តិករនានាក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ។ យុទ្ធសាស្ត្រក៏បានដាក់

ឱ្យអនុវត្តនូវការប្តេជ្ញារបស់រាជរដ្ឋាភិបាលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ដែលមានចែងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៊ូសានស្តីពីប្រសិទ្ធភាពក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

រាជរដ្ឋាភិបាលបានរៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដើម្បីធានាការបន្តអនុវត្ត ដោយផ្អែកលើវឌ្ឍនភាពដែលសម្រេចបានក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ កន្លងមក ។ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ នឹងរួមចំណែកដោះស្រាយបញ្ហាប្រឈម និងក្តាប់ឱ្យបាននូវកាលានុវត្តភាព ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ពិសេសក្នុងបរិការណ៍នៃការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មសកល និងក្នុងប្រទេស ។ ការរៀបចំយុទ្ធសាស្ត្រនេះបានទទួលធាតុចូលពីលទ្ធផលនៃការធ្វើអង្កេត ឆ្នាំ២០១៨ ស្តីពីភាពជាដៃគូសកលសម្រាប់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ដែលកម្ពុជាបានចូលរួម និងការវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តយន្តការក្រុមការងារបច្ចេកទេសចម្រុះ ដែលបានអនុវត្តនាពាក់កណ្តាលឆ្នាំ២០១៨ ។ លើមូលដ្ឋាននេះ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ ត្រូវបានរៀបចំដោយផ្អែកលើសក្ខីកម្ម ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ជាតិ ទន្ទឹមនឹងការផ្តោតលើលទ្ធផលដែលត្រូវអនុវត្តឱ្យបានសម្រេច ។

ទន្ទឹមនឹងការកើនឡើងខាងលទ្ធភាពហិរញ្ញវត្ថុរបស់កម្ពុជាសម្រាប់ជំរុញការអភិវឌ្ឍជាតិ, ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍នៅរក្សាតួនាទីសំខាន់ ទាំងប្រភពហិរញ្ញប្បទានសម្រាប់ការវិនិយោគ ក៏ដូចជាផ្តល់លទ្ធភាពឱ្យកម្ពុជាទទួលបាននូវបច្ចេកវិទ្យា, នវានុវត្តន៍, បណ្តាញការងារ និងដំណោះស្រាយផ្នែកគោលនយោបាយ ។ រាជរដ្ឋាភិបាលទទួលស្គាល់អំពីសារៈសំខាន់នៃការបង្កើនចំណូលក្នុងប្រទេស ដើម្បីបង្ហាញភាពជាម្ចាស់, ការប្តេជ្ញា និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការឈានទៅសម្រេចគោលដៅនៃការអភិវឌ្ឍជាតិ ទន្ទឹមនឹងការបន្តធ្វើការងារជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ។

## II. បរិការណ៍នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ប្រកបដោយជោគជ័យ, ការរៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ត្រូវឆ្លើយតបទៅនឹងបរិការណ៍កម្ពុជា, ជវភាពតំបន់ និងសកលលោក ។ លើសពីនេះ ក៏ត្រូវផ្អែកលើសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ ២០១៤-២០១៨ កន្លងមក ទន្ទឹមនឹងការប្រឹងប្រែងដោះស្រាយបញ្ហាប្រឈម និងការទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពរបស់កម្ពុជា ។

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល បានរំលេចសមិទ្ធផលសំខាន់ៗជាច្រើន ដែលជាមូលដ្ឋានសម្រាប់រៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ នេះ ។ សមិទ្ធផលទាំងនេះរួមមាន ÷ ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការបន្តរក្សាកំណើនសេដ្ឋកិច្ចទូលំទូលាយ, ការប្តេជ្ញាបន្តអនុវត្តការកែទម្រង់អភិបាលកិច្ច និងការលើកកម្ពស់នីតិរដ្ឋ, វឌ្ឍនភាពក្នុងវិស័យសង្គម-សេដ្ឋកិច្ច ពិសេសក្នុងវិស័យអប់រំ និងសុខាភិបាល ក៏ដូចជាការផ្លាស់ប្តូរជាវិជ្ជមាននៃរចនាសម្ព័ន្ធសេដ្ឋកិច្ច, ការជំរុញឧស្សាហូបនីយកម្ម និងពិពិធកម្មសេដ្ឋកិច្ច ។

ក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ រាជរដ្ឋាភិបាលទទួលស្គាល់តួនាទីរបស់ដៃគូអភិវឌ្ឍន៍ ដែលបានរួមចំណែកក្នុង

ការសម្រេចសមិទ្ធផលទាំងនេះ ។ ក្នុងន័យនេះ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.ន) បានអនុវត្តការងារយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងការកៀរគរ និងគ្រប់គ្រងធនធានសហប្រតិបត្តិការ ព្រមទាំងសម្របសម្រួលកិច្ចពិគ្រោះយោបល់ផ្នែកគោលនយោបាយជាមួយនឹងដៃគូទាំងនេះ ។

ក.អ.ក/គ.ជ.ន បានកត់ត្រា និងវិភាគលំហូរហិរញ្ញប្បទានសហប្រតិបត្តិការប្រចាំឆ្នាំ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកិច្ចពិគ្រោះយោបល់ផ្នែកគោលនយោបាយ ។ ទំហំហិរញ្ញប្បទានសហប្រតិបត្តិការបានធ្លាក់ចុះបន្តិចម្តងៗ បន្ទាប់ពីបានហក់ឡើងដល់កម្រិតខ្ពស់បំផុត គឺ ១.៥០០ លានដុល្លារ ក្នុងឆ្នាំ២០១២ ។ និន្នាការនេះមានសង្គតិភាពជាមួយនឹងស្ថានភាពទូទៅនៃបណ្តាប្រទេស ដែលស្ថិតក្នុងអន្តរកាលឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យម ។ ទន្ទឹមនឹងការកើនឡើងឆាប់រហ័សនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស), អនុបាតនៃហិរញ្ញប្បទានសហប្រតិបត្តិការ ធៀបនឹង ផ.ស.ស បានធ្លាក់ចុះមកត្រឹមរង្វង់ ៦% ក្នុងឆ្នាំ២០១៧ ។ ការធ្លាក់ចុះនៃហិរញ្ញប្បទានឥតសំណងត្រូវបានបំពេញដោយការផ្តល់ឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីសំខាន់ៗ ។ ឥណទានសម្បទានមានទំហំកាន់តែធំឡើងៗ ធៀបនឹងហិរញ្ញប្បទានឥតសំណង នាពេលអនាគត ក្នុងខណៈដែលកម្ពុជាកំពុងរៀបចំខ្លួនឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ដែលដំណើរការចាកចេញនេះនឹងអាចចាប់ផ្តើមក្នុងឆ្នាំ២០២១ ។

**<u>និន្នាការសំខាន់ៗនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ</u>**







<u>ប្រភពទិន្នន័យ</u> : ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការរបស់ ក.អ.ក/គ.ជ.ន

ដោយសារការធ្លាក់ចុះនៃហិរញ្ញប្បទានសហប្រតិបត្តិការ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ទៅលើស័ក្តិសិទ្ធិភាព និងលទ្ធផលនៃភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ។ ក្នុងន័យនេះ ក.អ.ក/គ.ជ.ន បានបន្តតាមដានវឌ្ឍនភាពក្នុងការអនុវត្តសូចនាករស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ដែលបានឯកភាពក្នុងវេទិកាស្តីពីភាពជាដៃគូសកល ហើយដែលត្រូវបានរំលេចក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ ។ រីឯសក្ខីកម្មដែលទទួលបានពីការធ្វើអង្កេតភាពជាដៃគូសកល ឆ្នាំ២០១៨ ក៏ត្រូវបានប្រើប្រាស់សម្រាប់រៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ។ លទ្ធផលនៃការធ្វើអង្កេតនេះបានរំលេចអំពីតម្រូវការចាំបាច់ក្នុងការបន្តអនុវត្តការប្តេជ្ញាស្តីពីភាពជាដៃគូ ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ÷

- ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល តាមរយៈការអនុវត្តគោលនយោបាយ ដើម្បីពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន
- គៀរគរធនធានហិរញ្ញប្បទានពីគ្រប់ប្រភព ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា
- រក្សា និងពង្រីកកិច្ចពិគ្រោះយោបល់ផ្នែកគោលនយោបាយជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់
- រៀបចំខ្លួនឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច និង
- ចូលរួមក្នុងយន្តការស្តីពីភាពជាដៃគូ និងស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ក្នុងកម្រិតតំបន់ និងសកល ។

តារាងខាងក្រោមបង្ហាញថា រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានសម្រេចវឌ្ឍនភាពជាបន្តបន្ទាប់ ក្នុងការអនុវត្តការប្តេជ្ញាស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ និងភាពជាដៃគូ ដែលបានឯកភាពក្នុងវេទិកាកំពូល នៅទីក្រុងប៊ូសាន ក្នុងឆ្នាំ២០១១ ។

| សូចនាករស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍សម្រាប់ភាពជាដៃគូសកល | ២០១៣ | ២០១៥ | ២០១៧ |
|---|---|---|---|
| ១a- ការប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិដោយដៃគូអភិវឌ្ឍន៍ | - | ៧៥% | ៦៤% |
| ១b- ការពង្រឹងក្របខណ្ឌលទ្ធផលជាតិរបស់ប្រទេសជាដៃគូ | | | ៩៣% |
| ២- បរិស្ថានអំណោយផលសម្រាប់សង្គមស៊ីវិល និងស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ | បានអនុវត្ត | បានអនុវត្ត | ៥៩% |
| ៣- គុណភាពនៃកិច្ចពិគ្រោះយោបល់ រវាងរដ្ឋ និងឯកជន | បានអនុវត្ត | បានអនុវត្ត | ៥៩% |
| ៤- ការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | បានអនុវត្ត | បានអនុវត្ត | ១០០% |
| ៥a- ភាពទស្សន៍ទាយបានប្រចាំឆ្នាំនៃហិរញ្ញប្បទានសហប្រតិបត្តិការ | ៨៤% | ៨៧% | ៩៦% |
| ៥b- ភាពទស្សន៍ទាយបានក្នុងរយៈពេលមធ្យមនៃហិរញ្ញប្បទានសហប្រតិបត្តិការ | ៩៨% | ៩៥% | ៩៣% |
| ៦- ហិរញ្ញប្បទានសហប្រតិបត្តិការកត់ត្រាក្នុងច្បាប់ថវិកា និងអនុម័តដោយរដ្ឋសភា | ៧៩% | ៧៩% | ៨៣% |
| ៧- គណនេយ្យភាពទ្វេទិស តាមរយៈការត្រួតពិនិត្យប្រកបដោយបរិយាប័ន្ន | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត |
| ៨- សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | បានអនុវត្ត | បានអនុវត្ត | មិនបានអនុវត្ត |
| ៩a- គុណភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (CPIA: ១=ទាប, ៦=ខ្ពស់) | ៣,៥ | ៣,៤ | - |
| ៩b- ការប្រើប្រាស់ប្រព័ន្ធជាតិដោយដៃគូអភិវឌ្ឍន៍ | ៣២% | ៤៩% | ៦១% |
| ១០- ហិរញ្ញប្បទានគ្មានភ្ជាប់លក្ខខណ្ឌ | ៨៥% | ៧៩% | - |

កំណត់សម្គាល់ : -សូចនាករទី៩a និងទី១០ ត្រូវបានវាស់វែងក្នុងកម្រិតសកល

-សូចនាករទី ៨ (ឆ្នាំ២០១៧) ពាក់ព័ន្ធនឹងប្រព័ន្ធថវិកាសម្រាប់យេនឌ័រ

ប្រភពទិន្នន័យ : ការធ្វើអង្កេតនៃដៃគូសកលស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ

រាជរដ្ឋាភិបាលបានសម្រេចវឌ្ឍនភាពក្នុងការពង្រឹងភាពជាម្ចាស់ និងការអភិវឌ្ឍដោយផ្តោតលើលទ្ធផល ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៧, ក្របខណ្ឌលទ្ធផលជាតិត្រូវបានពង្រឹង និងប្រើប្រាស់កាន់តែទូលំទូលាយ ។ ការប្រើប្រាស់ប្រព័ន្ធជាតិ ពិសេសពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកើនឡើងពី ៤៩% នាឆ្នាំ២០១៥ ដល់ ៦១% ក្នុងឆ្នាំ២០១៧ ។ ហិរញ្ញប្បទានសហប្រតិបត្តិការ ចំនួន៨៣%ត្រូវបានកត់ត្រាក្នុងថវិការដ្ឋ ទន្ទឹមនឹងភាពទស្សន៍ទាយបាននៃការបើកផ្តល់ហិរញ្ញប្បទានប្រចាំឆ្នាំ បានកើនដល់ ៩៦% ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានជំរុញ និងលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាប័ន្នក្នុងការអភិវឌ្ឍ ដោយបន្តផ្តោតអាទិភាពទៅលើកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល និង

ផ្នែកឯកជន ព្រមទាំងលើកកម្ពស់បរិយាកាសអំណោយផលដើម្បីអង្គការសង្គមស៊ីវិលបានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ ។ លើសពីនេះ ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ បានពង្រឹង និងលើកកម្ពស់តម្លាភាព តាមរយៈការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ។ រីឯគណនេយ្យភាពទ្វេទិសត្រូវបានវាស់វែង តាមរយៈការអនុវត្តយន្តការក្រុមការងារបច្ចេកទេសចម្រុះ និងសូចនាករតាមដានរួមគ្នា ។

បញ្ហាសំខាន់ចំពោះមុខគឺការបង្កើនការប្រើប្រាស់ប្រព័ន្ធជាតិ ។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី ៣ ដែលបានផ្តោតជាសំខាន់ទៅលើការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ត្រូវបានពង្រីកការអនុវត្តនៅគ្រប់ក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល តាមរយៈការដាក់ឲ្យអនុវត្តកាន់តែច្រើន នូវទិសដៅ និងសូចនាករដែលផ្តោតលើលទ្ធផល ។ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានបញ្ជាក់អំពីសារៈសំខាន់នៃថវិកា ដែលជាឧបករណ៍សម្រាប់តម្រឹមធនធានជាមួយអាទិភាពជាតិ ទន្ទឹមនឹងការបង្កើនការប្រើប្រាស់ប្រព័ន្ធថវិការដ្ឋ ដើម្បីត្រួតពិនិត្យ និងតាមដានលទ្ធផល ព្រមទាំងវិភាជធនធាន ។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងដំណាក់កាលបន្ទាប់ ដែលបញ្ចូលហិរញ្ញប្បទានសហប្រតិបត្តិការទៅក្នុងប្រព័ន្ធថវិការដ្ឋ បានក្លាយជាការងារអាទិភាពរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់ ក្នុងបណ្តាឆ្នាំខាងមុខ ។

**<u>ការព្យាករណ៍ហិរញ្ញវត្ថុសម្រាប់កិច្ចអភិវឌ្ឍន៍ ឆ្នាំ២០២៥</u>**




<u>ប្រភពទិន្នន័យ</u>: ការធ្វើបច្ចុប្បន្នភាពនៃការវាយតម្លៃស្ថានភាពហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ ឆ្នាំ២០១៨ របស់ ក.អ.ក/គ.ជ.នា

ផ្អែកតាមសារៈសំខាន់កាន់តែខ្លាំងឡើងៗនៃថវិការដ្ឋក្នុងការអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលបាន និងកំពុងបន្តខិតខំកៀរគរចំណូលក្នុងប្រទេស ។ ជាក់ស្តែង ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ អនុបាតនៃចំណូលក្នុងប្រទេស ធៀបនឹង ផ.ស.ស បានកើនពី ១៥,១៥% ក្នុងឆ្នាំ២០១៣ ដល់ ២០,២៥% ក្នុងឆ្នាំ២០១៧ ។ ទន្ទឹមនឹងនេះ របាយការណ៍ស្តីពីការវាយតម្លៃស្ថានភាពហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ បានព្យាករណ៍ថា នៅឆ្នាំ២០២៥ ប្រមាណជិត ៤០% នៃហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ មានប្រភពពីចំណូលក្នុងប្រទេស ។ នេះបញ្ជាក់ច្បាស់ថា ដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍដើម្បីសម្រេចចក្ខុវិស័យអភិវឌ្ឍន៍ជាតិ នឹងត្រូវផ្អែកកាន់តែខ្លាំងឡើងៗទៅលើធនធានអភិវឌ្ឍន៍ផ្ទាល់របស់រាជរដ្ឋាភិបាល ។

ប្រភពហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍សំខាន់មួយទៀត គឺធនធានរបស់វិស័យឯកជន ។ វិស័យឯកជន គឺជា

ក្បាលម៉ាស៊ីននៃកំណើន ក្នុងមួយទស្សវត្សរ៍កន្លងមក ដែលបានរួមចំណែកធនធានប្រមាណ ២២,៧០% ធៀបនឹង ផ.ស.ស ក្នុងឆ្នាំ២០១៧ ក្នុងនោះការវិនិយោគឯកជនក្នុងស្រុក មានប្រមាណ ១១,៨០% និងការវិនិយោគផ្ទាល់ពីបរទេស មានប្រមាណ ១១% ធៀបនឹង ផ.ស.ស ។

ទោះជាយ៉ាងនេះក្តី, ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយមហិច្ឆតារបស់រាជរដ្ឋាភិបាល ពិសេស គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ទាមទារការកៀរគរធនធានបន្ថែមពីតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធជាច្រើន ទៀត ។ របាយការណ៍ស្តីពីការវាយតម្លៃស្ថានភាពហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍បានបង្ហាញបន្ថែមថា កម្ពុជានៅ មានសក្តានុពលជាច្រើន សម្រាប់កៀរគរធនធានពីប្រភពដទៃ និងសម្របសម្រួលធនធានទាំងនេះ រួមទាំងធនធាន ពីវិស័យឯកជន និងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ផងដែរ ។

សមិទ្ធផល, បញ្ហាប្រឈម និងកាលានុវត្តភាពនានាដែលមានលក្ខណៈសមស្របទៅនឹងដំណាក់កាលបន្ទាប់នៃ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ មានដូចខាងក្រោម ÷

<u>**សមិទ្ធផល**</u>

- រាជរដ្ឋាភិបាលបានអនុវត្តការប្តេជ្ញាស្តីពីភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ប្រកបដោយប្រសិទ្ធភាព តាមរយៈ ការសម្រេចបានលទ្ធផលជាក់ស្តែង ស្របតាមខ្លឹមសារនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។
- ប្រព័ន្ធ និងសមត្ថភាពស្ថាប័ន បានពង្រឹងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរ និងការ គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

<u>**បញ្ហាប្រឈម**</u>

- ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ត្រូវឆ្លើយតបទៅនឹងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើទំនើបកម្ម សេដ្ឋកិច្ច ឆ្ពោះទៅអនុវត្តម៉ូដែលសេដ្ឋកិច្ចដែលផ្តោតលើកំណើនប្រកបដោយបរិយាប័ន្ន និងទូលំទូលាយ ។
- ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ និងការកៀរគរធនធានថ្មី សម្រាប់គាំទ្រការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយ ចីរភាពកម្ពុជា ទន្ទឹមនឹងការរៀបចំខ្លួនឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ក្នុងពេលដែល ទំហំហិរញ្ញប្បទានសហប្រតិបត្តិការបានធ្លាក់ចុះ ។

<u>**កាលានុវត្តភាព**</u>

- ការអភិវឌ្ឍកម្រិតខ្ពស់, ស្ថានភាពហិរញ្ញវត្ថុសាធារណៈល្អប្រសើរ និងការកែទម្រង់វិស័យសាធារណៈប្រកប ដោយប្រសិទ្ធភាព គឺជាមូលដ្ឋានចាំបាច់សម្រាប់រាជរដ្ឋាភិបាលបន្តដឹកនាំភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ។
- ការប្តេជ្ញាអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងភាពជាដៃគូទីក្រុងប៊ូសាន បានបំពេញបន្ថែម ឱ្យក្របខណ្ឌអភិវឌ្ឍន៍ជាតិ និងជាយន្តការសម្រាប់រាជរដ្ឋាភិបាលពង្រឹងភាពជាដៃគូឱ្យមានប្រសិទ្ធភាព ។

ស្ថានភាពទូទៅនៃកិច្ចអភិវឌ្ឍន៍កម្ពុជាមានលក្ខណៈអំណោយផល ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលប្តេជ្ញាបន្ត ដឹកនាំ និងពង្រឹងភាពជាដៃគូពហុភាគី ដែលអាចបង្កើនកាលានុវត្តភាពសម្រាប់កៀរគរធនធាន ទន្ទឹមនឹងការអនុវត្តការកែ ទម្រង់នានារបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលទទួលស្គាល់អំពីការបន្តធ្លាក់

ចុះនៃហិរញ្ញប្បទានសហប្រតិបត្តិការ ប៉ុន្តែ រាជរដ្ឋាភិបាលមានលទ្ធភាពពេញលេញក្នុងការកៀរគរធនធានផ្ទាល់ ទន្ទឹមនឹងបន្តដឹកនាំតួអង្គអភិវឌ្ឍន៍ដទៃទៀត ក្នុងយន្តការនៃភាពជាដៃគូថ្មី ។ លើមូលដ្ឋាននេះ តួនាទីនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ គឺការគ្រប់គ្រងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍សម្រាប់ប្រើប្រាស់ឱ្យអស់នូវសក្តានុពលនៃភាពជាដៃគូទាំងនេះ ។

## III. គោលដៅចម្បង, ទិសដៅជាយុទ្ធសាស្ត្រ និងក្របខណ្ឌលទ្ធផល

ដើម្បីតម្រឹមជាមួយនឹងចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍ជាតិ, យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ បានកំណត់គោលដៅចម្បងចំនួន ១ និងទិសដៅជាយុទ្ធសាស្ត្រចំនួន ៣ ។ ដូចបានបញ្ជាក់ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ រាជរដ្ឋាភិបាលបានកំណត់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ស្របតាមបរិការណ៍កម្ពុជា ដើម្បីសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។ ក្នុងន័យនេះ គោលបំណងសំខាន់នៃយុទ្ធសាស្ត្រនេះ គឺការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានពីគ្រប់ប្រភពទាំងអស់ ដើម្បី៖ ក) មានធនធានច្រើនសម្រាប់ការអភិវឌ្ឍ, ខ) តម្រឹមធនធានជាមួយនឹងអាទិភាពអភិវឌ្ឍន៍ជាតិ និង គ) សម្រេចបានលទ្ធផលល្អប្រសើរ ។

ស្របតាមអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ដើម្បីអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ រាជរដ្ឋាភិបាលបានកំណត់ទិសដៅ, ចំណុចដៅ និងសូចនាករច្បាស់លាស់ ។ ដោយមានសង្គតិភាពជាមួយនឹងការកែទម្រង់របស់រាជរដ្ឋាភិបាល ពិសេសការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យុទ្ធសាស្ត្រនេះបានប្រើប្រាស់អភិក្រមព័ត៌មានសមិទ្ធកម្ម តាមរយៈការដាក់ឱ្យអនុវត្តនូវសូចនាករដែលអាចវាស់វែងបាន ។ ក្នុងន័យនេះ យុទ្ធសាស្ត្របានកំណត់ក្របខណ្ឌលទ្ធផលផ្ទាល់ខ្លួន ដោយផ្អែកលើ៖ ក) គោលដៅនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, ខ) ក្របខណ្ឌតាមដាននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និង គ) ការប្តេជ្ញាសកលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ដែលបានចែងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៊ូសាន ។

ផ្អែកលើគោលដៅចម្បង និងទិសដៅជាយុទ្ធសាស្ត្រខាងលើ, សូចនាករមួយចំនួនត្រូវបានកំណត់ សម្រាប់តាមដានជាប្រចាំ ។ រាជរដ្ឋាភិបាលនឹងបន្តតាមដានសូចនាករទាំងនេះ តាមរយៈការប្រើប្រាស់ព័ត៌មានក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដែលធ្លាប់ទទួលជោគជ័យក្នុងការតាមដានការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ ក៏ដូចជាក្នុងការតាមដានការអនុវត្តការប្តេជ្ញាទីក្រុងប៊ូសានក្នុងឆ្នាំ២០១៣, ឆ្នាំ២០១៥ និងឆ្នាំ២០១៧ ។ ដៃគូអភិវឌ្ឍន៍នឹងបន្តរាយការណ៍ការបើកផ្តល់ហិរញ្ញប្បទានរបស់ខ្លួន ក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ចំនួន ២ ដងក្នុងមួយឆ្នាំ គឺ៖ លើកទី១ នាត្រីមាសទី១ រៀងរាល់ឆ្នាំ ដើម្បីផ្តល់តួលេខប៉ាន់ស្មានការបើកផ្តល់ហិរញ្ញប្បទានក្នុងឆ្នាំកន្លងមក និងលើកទី២ នាត្រីមាសទី៣ ដើម្បីបញ្ជាក់ការបើកផ្តល់ហិរញ្ញប្បទានជាក់ស្តែងក្នុងឆ្នាំកន្លងមក និងធ្វើការព្យាករណ៍ការបើកផ្តល់ហិរញ្ញប្បទានសម្រាប់ឆ្នាំបន្ទាប់ ។

<table>
<tr><th colspan="2">គោលដៅចម្បង និងទិសដៅជាយុទ្ធសាស្ត្រ សម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា</th></tr>
<tr><td colspan="2">គោលដៅចម្បង : កៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានអភិវឌ្ឍន៍ទាំងអស់ ដើម្បីប្រើប្រាស់ធនធានទាំងនេះឲ្យមានប្រសិទ្ធភាពខ្ពស់ សំដៅឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍កម្ពុជាដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ក៏ដូចជាយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ។</td></tr>
<tr><td>ទិសដៅជាយុទ្ធសាស្ត្រទី ១ : ភាពជាម្ចាស់<br>ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរ និងគ្រប់គ្រងធនធាន</td><td>ការប្តេជ្ញាស្តីពីភាពជាដៃគូសកលត្រូវបានអនុវត្ត ស្របតាមបរិការណ៍ និងអាទិភាពកម្ពុជា ។ ការប្រើប្រាស់ធនធានក្នុង និងក្រៅប្រទេស ត្រូវបំពេញឲ្យគ្នាទៅវិញទៅមកសម្រាប់គាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងអាទិភាពតាមវិស័យ និងការកែទម្រង់ ដែលមានសង្គតិភាពជាមួយនឹងគោលដៅអភិវឌ្ឍន៍ជាតិ ។</td></tr>
<tr><td>ទិសដៅជាយុទ្ធសាស្ត្រទី ២ : ភាពជាដៃគូ<br>ការគាំទ្រប្រកបដោយសង្គតិភាព និងការសម្របសម្រួល ដើម្បីលើកកម្ពស់ការផ្តល់សេវា និងពង្រឹងប្រព័ន្ធជាតិ</td><td>យន្តការភាពជាដៃគូ បានកំណត់ និងប្រើប្រាស់អភិក្រមដែលផ្តោតលើការរៀបចំកម្មវិធីរួមគ្នា, ការសម្របសម្រួលក្នុងការអនុវត្ត និងការពង្រឹងប្រព័ន្ធជាតិ ដែលរួមមានការគាំទ្រការកែទម្រង់របស់រាជរដ្ឋាភិបាល និងជំរុញប្រសិទ្ធភាពនៃយន្តការភាពជាដៃគូ ជាមួយតួអង្គមិនមែនរដ្ឋ រួមទាំងអង្គការសង្គមស៊ីវិល និងវិស័យឯកជនផងដែរ ។</td></tr>
<tr><td>ទិសដៅជាយុទ្ធសាស្ត្រទី ៣ : លទ្ធផល<br>ប្រព័ន្ធតាមដានរឹងមាំ និងគោលការណ៍ស្តីពីគណនេយ្យភាពទ្វេទិស គឺជាមូលដ្ឋានសម្រាប់ពង្រឹងភាពជាដៃគូដោយផ្អែកលើសក្ខីកម្ម</td><td>ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ និងធនធាន ត្រូវបានប្រើប្រាស់ជាកាតាលីករ ដើម្បីសម្រេចលទ្ធផល ។ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល និងស្របតាមការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំថវិកាព័ត៌មានសមិទ្ធកម្ម, រចនាសម្ព័ន្ធសម្របសម្រួល និងពិគ្រោះយោបល់ រួមទាំងសូចនាករតាមដានរួមគ្នា នឹងផ្តោតទៅលើការកំណត់ចំណុចដៅ, ការតាមដានវឌ្ឍនភាព និងរបាយការណ៍អំពីលទ្ធផល ។</td></tr>
</table>

វឌ្ឍនភាពនៃការអនុវត្តក្របខណ្ឌលទ្ធផល និងសូចនាករ នឹងត្រូវត្រួតពិនិត្យតាមរយៈរបាយការណ៍វាយតម្លៃខាងគុណភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, របាយការណ៍ស្តីពីវឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួមគ្នា និងរបាយការណ៍ប្រចាំឆ្នាំស្តីអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ ការត្រួតពិនិត្យនេះក៏បានទទួលធាតុចូលបន្ថែមពីកិច្ចប្រជុំនៃបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ, របាយការណ៍ស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (រួមទាំងរបាយការណ៍ដោយស្ម័គ្រចិត្តស្តីពីវឌ្ឍនភាពនៃការអនុត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលកម្ពុជាគ្រោងរៀបចំក្នុងឆ្នាំ២០១៩) និងកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក៏ដូចជាការត្រួតពិនិត្យវឌ្ឍនភាពតាមវិស័យ ។ ទាំងនេះគឺជាធាតុចូលបន្ថែម សម្រាប់រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។

| សូចនាករសម្រាប់តាមដានស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា | | | |
|---|---|---|---|
| | **សូចនាករ** | **ប្រភពទិន្នន័យ** | **ស្ថាប័ន** |
| **គោលដៅចម្បង**<br>កៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានអភិវឌ្ឍន៍ទាំងអស់ ដើម្បីប្រើប្រាស់ធនធានទាំងនេះប្រកបដោយស័ក្តិសិទ្ធិភាព និងលទ្ធផលខ្ពស់ | ការត្រួតពិនិត្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងសូចនាករតាមដានរួមគ្នាតាមវិស័យ ឆ្នាំ២០១៩-២០២៣ នឹងវាយតម្លៃវឌ្ឍនភាពនៃកិច្ចអភិវឌ្ឍន៍ នៅកម្រិតលទ្ធផល និងធាតុចេញ ក៏ដូចជាវាយតម្លៃអំពីការផ្តល់ហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ ។ | -ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា<br>-បច្ចុប្បន្នភាពនៃការវាយតម្លៃស្ថានភាពហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ១៧.៣)<br>-របាយការណ៍ស្តីពីការអនុវត្តសូចនាករតាមដានរួមគ្នា (ការផ្សារភ្ជាប់រវាងភាពជាម្ចាស់ និងលទ្ធផល) | -ក្រសួងផែនការ<br>-ក.អ.ក/គ.ជ.នា<br>-ក.អ.ក/គ.ជ.នា |
| **ទិសដៅទី ១- ភាពជាម្ចាស់**<br>ការប្តេជ្ញាស្តីពីភាពជាដៃគូសកល ត្រូវបានអនុវត្តដោយមានសង្គតិភាពជាមួយនឹងបរិការណ៍ និងអាទិភាពរបស់កម្ពុជា | ១ក- ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ (ដុល្លារ និងអនុបាតធៀបនឹង ផ.ស.ស)<br>១ខ- ការប្រើប្រាស់ក្របខណ្ឌលទ្ធផលដោយដៃគូអភិវឌ្ឍន៍ (ទិន្នន័យមូលដ្ឋាន: ៦៤% និងចំណុចដៅ: ៨០%) | -ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ១៧.២.១)<br>-ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ (របាយការណ៍ស្តីពីការធ្វើអង្កេតទីក្រុងប៊ូសាន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ១៧.១៥.១) | -ក.អ.ក/គ.ជ.នា<br>-ក.អ.ក/គ.ជ.នា<br>-ក្រសួងផែនការ |
| **ទិសដៅទី ២ - ភាពជាដៃគូ**<br>ការគាំទ្រប្រកបដោយសង្គតិភាព និងការសម្របសម្រួល ដើម្បីលើកកម្ពស់ការផ្តល់សេវា និងពង្រឹងប្រព័ន្ធជាតិ | ២ក- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ទិន្នន័យមូលដ្ឋាន: ៧៦% និងចំណុចដៅ: ៨៥%)<br>២ខ- ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ (ទិន្នន័យមូលដ្ឋាន: ៤៤% និងចំណុចដៅ: ៦០%)<br>២គ- ការពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពភាពជាដៃគូរបស់ក្រុមការងារបច្ចេកទេសចម្រុះ (រួមទាំងការវាយតម្លៃពីការគាំទ្រការអភិវឌ្ឍសមត្ថភាព) | -ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ (របាយការណ៍ស្តីពីការធ្វើអង្កេតទីក្រុងប៊ូសាន)<br>-របាយការណ៍នៃកិច្ចប្រជុំបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ<br>-របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ (របាយការណ៍ប្រចាំឆ្នាំ រួមទាំងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ១៧.៩.១ ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស និងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក.អ.ក/គ.ជ.នា<br>-ក.អ.ក/គ.ជ.នា<br>-ក.អ.ក/គ.ជ.នា |
| **ទិសដៅទី ៣ - លទ្ធផល**<br>ប្រព័ន្ធតាមដានរឹងមាំ និងគោលការណ៍ស្តីពីគណនេយ្យភាពទ្វេទិស គឺជាមូលដ្ឋានសម្រាប់ពង្រឹងភាពជាដៃគូដោយផ្អែកលើសក្ខីកម្ម | ៣ក- ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ (ទិន្នន័យមូលដ្ឋាន: ៨៣% និង ចំណុចដៅ: ៩៥%) និងការបើកផ្តល់តាមកាលបរិច្ឆេទគ្រោងទុក (ទិន្នន័យមូលដ្ឋាន: ៩១% និងចំណុចដៅ: ៩៥%)<br>៣ខ- កិច្ចប្រជុំបណ្តាញក្រុមការងារបច្ចេកទេសចម្រុះប្រចាំឆ្នាំ និងការវាយតម្លៃរួមគ្នាលើវឌ្ឍនភាពរួមទាំងសូចនាករតាមដានរួមគ្នា | -ថវិការដ្ឋ និងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ (របាយការណ៍ស្តីពីការធ្វើអង្កេតទីក្រុងប៊ូសាន)<br>-របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ (របាយការណ៍ប្រចាំឆ្នាំ)<br>-របាយការណ៍ស្តីពីកិច្ចប្រជុំបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ១៧.១៤.១) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក.អ.ក/គ.ជ.នា<br>-ក.អ.ក/គ.ជ.នា<br>-ក.អ.ក/គ.ជ.នា |

## IV. គោលការណ៍, យន្តការ, ឧបករណ៍ និងការរៀបចំស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រ និងត្រួតពិនិត្យ

គោលការណ៍នានាដែលបានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨ ត្រូវបានអនុវត្ត និងរួមចំណែកពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។ វឌ្ឍនភាពទាំងនេះរួមមាន÷ ក) ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងដំណើរការយន្តការភាពជាដៃគូ ស្របតាមការប្រែប្រួលនៃបរិការណ៍អភិវឌ្ឍន៍, ខ) ការទទួលស្គាល់រួមគ្នាអំពីតម្លៃនៃជំនឿទុកចិត្ត និងគណនេយ្យភាពទ្វេទិស និង គ) តម្រូវការក្នុងការពង្រឹងប្រព័ន្ធជាតិ និងសមត្ថភាពស្ថាប័ន ទន្ទឹមនឹងការផ្តោតលើលទ្ធផល ។ គោលការណ៍ទាំងនេះគឺជាមូលដ្ឋានគ្រឹះដើម្បីរៀបចំយន្តការ និងឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ ។

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានគូសបញ្ជាក់អំពីភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨ ។ យុទ្ធសាស្ត្រចតុកោណបានរំលេចអំពីការប្រែប្រួលនៃបរិការណ៍អភិវឌ្ឍន៍ ពិសេសសមត្ថភាពហិរញ្ញវត្ថុផ្ទាល់របស់កម្ពុជា សម្រាប់ដឹកនាំកិច្ចអភិវឌ្ឍន៍ជាតិ ។ បទពិសោធន៍ក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូកន្លងមក គួបផ្សំនឹងការប្រែប្រួលបរិការណ៍, បញ្ហាប្រឈម និងកាលានុវត្តភាព បានផ្តល់ជាមូលដ្ឋានក្នុងការរៀបចំគោលការណ៍, យន្តការ និងឧបករណ៍នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៩-២០២៣ ដែលរួមមាន÷

### ក- គោលការណ៍

ស្របតាមយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, គោលការណ៍ស្តីពីភាពជាដៃគូ ត្រូវបានរៀបចំ ដោយផ្សារភ្ជាប់ទៅនឹងទិសដៅ/លទ្ធផលទាំងបី ដើម្បីតម្រង់ទិសការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ។ គោលការណ៍ទាំងនេះរួមមានដូចខាងក្រោម÷

**១- _ភាពជាម្ចាស់_**

- រាជរដ្ឋាភិបាលប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដោយឈរលើគោលការណ៍ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងទំនាក់ទំនងដែលផ្អែកលើការជឿទុកចិត្ត និងការគោរពគ្នាទៅវិញទៅមក តាមរយៈការដាក់ឱ្យអនុវត្តនូវក្របខណ្ឌគ្រប់គ្រងដោយផ្តោតលើលទ្ធផល ។
- គោលការណ៍សកលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ នៅរក្សាភាពសមស្របសម្រាប់បន្តអនុវត្តក្នុងបរិការណ៍កម្ពុជា ហើយការវាយតម្លៃការអនុវត្តគោលការណ៍នេះនឹងត្រូវធ្វើឡើងតាមរយៈរបាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។

**២- _ភាពជាដៃគូ_**

- រាជរដ្ឋាភិបាលនឹងដឹកនាំភាពជាដៃគូប្រកបដោយបរិយាប័ន្ន ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីកៀរគរធនធាន និងសម្រេចបានលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។
- គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ត្រូវរួមចំណែកជំរុញកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច

ប្រកបដោយចីរភាព និងសមធម៌ តាមរយៈការបង្កើនសមត្ថភាពផលិត និងការពង្រឹងមូលធនមនុស្ស ។

- ការអភិវឌ្ឍសមត្ថភាពនៅតែជាទិសដៅសំខាន់មួយក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ គំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍសមត្ថភាព និងការផ្តល់ជំនួយបច្ចេកទេស ត្រូវផ្សារភ្ជាប់ទៅនឹងការពង្រឹងប្រព័ន្ធជាតិ តាមរយៈកម្មវិធីកែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ។

៣- <u>លទ្ធផល</u>

- យន្តការនៃភាពជាដៃគូ និងសម្របសម្រួលគ្រប់កម្រិត ត្រូវបញ្ជាក់អំពីទិសដៅអភិវឌ្ឍន៍ និងកំណត់ក្របខណ្ឌតាមដាន ហើយត្រូវផ្សារភ្ជាប់នឹងលទ្ធផល ដែលមានចែងក្នុងគោលនយោបាយ និងផែនការជាតិ និងវិស័យ ។
- ស្របតាមយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងយុទ្ធសាស្ត្រតាមវិស័យ, ការរៀបចំថវិការដ្ឋប្រចាំឆ្នាំត្រូវផ្អែកលើអភិក្រមព័ត៌មានសមិទ្ធកម្ម ។ ដំណើរការរៀបចំថវិកាបែបនេះនឹងតម្រង់ទិសការវិភាជធនធាន, កម្មវិធីនីយកម្ម, កិច្ចពិគ្រោះយោបល់ និងការតាមដាន ។

## ខ- យន្តការ និងឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រ និងត្រួតពិនិត្យ

ការផ្សារភ្ជាប់រវាងទិសដៅ ឬលទ្ធផល និងគោលការណ៍ គឺជាមូលដ្ឋានដើម្បីកំណត់យន្តការ និងឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ ។ គោលការណ៍ស្តីពីភាពជាម្ចាស់, ភាពជាដៃគូ និងលទ្ធផល នឹងតម្រង់ទិសការអនុវត្តយុទ្ធសាស្ត្រនេះ ដើម្បីធានាសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល រួមមាន÷

### ១- <u>ការបញ្ចូលហិរញ្ញប្បទានសហប្រតិបត្តិការក្នុងថវិការដ្ឋ</u>

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានបញ្ជាក់ច្បាស់ពីតួនាទីសំខាន់នៃថវិការដ្ឋ ដែលជាឧបករណ៍គន្លឹះសម្រាប់វិភាជធនធាន និងតាមដានលទ្ធផល ។ ថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកាដែលបានដាក់ឲ្យអនុវត្តក្នុងឆ្នាំ២០១៥ គឺជាការផ្លាស់ប្តូរទម្រង់ពីការគ្រប់គ្រងថវិកាតាមខ្ទង់ចំណាយ ទៅជាការគ្រប់គ្រងថវិកាសមិទ្ធកម្ម ដែលនេះគឺជាការអនុវត្តអភិក្រមដោយផ្តោតលើលទ្ធផល ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-ដំណាក់កាលទី ៣ ដែលអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ បានកំណត់ទិសដៅសម្រាប់បន្តពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដោយបានអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ។ ការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងការលើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ មានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ដូចខាងក្រោម÷

- យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា គឺជាផែនទីចង្អុលផ្លូវ សម្រាប់បញ្ចូលហិរញ្ញប្បទានសហប្រតិបត្តិការទៅក្នុងក្របខណ្ឌផែនការនីយកម្ម, ថវិកានីយកម្ម និងការត្រួតពិនិត្យ ។
- ក្របខណ្ឌលទ្ធផលត្រូវបានពង្រឹង និងតម្រឹមជាមួយអាទិភាពរបស់រាជរដ្ឋាភិបាល ដោយក្រសួង និងស្ថាប័នទាំងអស់ត្រូវរៀបចំថវិកា ឲ្យស្របតាមទិសដៅគោលនយោបាយ, កម្មវិធី និងអនុកម្មវិធី និងសកម្មភាពនានា

សម្រាប់ចរចាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- នាឆ្នាំ ២០២១ ថវិកាចរន្ត និងថវិកាមូលធន នឹងត្រូវដាក់បញ្ចូលគ្នា រួមទាំងហិរញ្ញប្បទានសហប្រតិបត្តិការ ។
- ក្របខណ្ឌថវិការយៈពេលមធ្យម (រយៈពេល ៣ ឆ្នាំ) គឺជាមូលដ្ឋានគ្រឹះសម្រាប់ពិភាក្សាហិរញ្ញប្បទានសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍ ។

ក្រសួង និងស្ថាប័ននីមួយៗ មានក្រុមការងារបច្ចេកទេសសម្រាប់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ជាទូទៅ ស្ថិតនៅក្នុងនាយកដ្ឋានថវិកា) ។ ក្រុមការងារនេះមានតួនាទីសម្របសម្រួលកិច្ចពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីបញ្ចូលធនធានសហប្រតិបត្តិការ ទៅក្នុងថវិការដ្ឋ ។ ទន្ទឹមនឹងនេះ ក៏ជាយន្តការពិភាក្សាទូលំទូលាយដើម្បីឲ្យការប្រើប្រាស់ហិរញ្ញប្បទានអភិវឌ្ឍន៍អាចឆ្លើយតបទៅនឹងគោលដៅ និងវិស័យជាច្រើន ។

## ២ -<u>កិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍</u>

ការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ បានបង្ហាញអំពីនិន្នាការនៃការផ្លាស់ប្តូរទម្រង់ពីកិច្ចពិគ្រោះយោបល់ពហុភាគី ទៅជាកិច្ចពិគ្រោះយោបល់ទ្វេភាគី ។ កិច្ចពិគ្រោះយោបល់ទ្វេភាគីបានដើរតួនាទីកាន់តែសំខាន់ឡើងៗ ដោយសារយន្តការនេះបានអនុញ្ញាតឲ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នីមួយៗ ពិភាក្សាលើបញ្ហានានាដែលពាក់ព័ន្ធនឹងការកំណត់អាទិភាព, ការរៀបចំកម្មវិធីនីយកម្ម, ការអនុវត្ត និងលទ្ធផលនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ។

ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ ក.អ.ក/គ.ជ.នា ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, កិច្ចពិគ្រោះយោបល់ទ្វេភាគីបានផ្តល់កាលានុវត្តភាព សម្រាប់ពិនិត្យវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈមជាក់ស្តែងក្នុងការអនុវត្តកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលបានកត់សម្គាល់ថា ដៃគូអភិវឌ្ឍន៍មួយចំនួនពុំទាន់បានប្រើប្រាស់កាលានុវត្តភាពនេះឲ្យអស់លទ្ធភាពនៅឡើយ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលលើកទឹកចិត្តឲ្យដៃគូអភិវឌ្ឍន៍ទាំងអស់បន្តអនុវត្តយន្តការកិច្ចពិគ្រោះយោបល់ទ្វេភាគីនេះ ជាមួយ ក.អ.ក/គ.ជ.នា សម្រាប់ហិរញ្ញប្បទានឥតសំណង និងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឥណទានសម្បទាន ។

យន្តការកិច្ចពិគ្រោះយោបល់ទ្វេភាគីអាចពិភាក្សាលើបញ្ហានានាផ្នែកគោលនយោបាយ និងកំណត់ទស្សនៈរួមគ្នា ព្រមទាំងឯកភាពលើសកម្មភាពដែលត្រូវអនុវត្ត ដូចជាការជំរុញអនុវត្តការប្តេជ្ញាលើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ (តារាងស្តីពីសមិទ្ធកម្មរបស់ដៃគូអភិវឌ្ឍន៍នីមួយៗក្នុងទំព័រទី១៧) ។ យន្តការនេះក៏អាចប្រើប្រាស់សម្រាប់ពិនិត្យភាពជាដៃគូ ក្នុងពេលដែលដៃគូអភិវឌ្ឍន៍បានបង្កើនលទ្ធភាពកៀរគរធនធាន ជាមួយរាជរដ្ឋាភិបាល និងវិស័យឯកជន ។ កិច្ចពិគ្រោះយោបល់ទ្វេភាគី និងការត្រួតពិនិត្យធនធានជាមួយដៃគូអភិវឌ្ឍន៍នីមួយៗ គឺជាវិធីសាស្ត្រសមស្របសម្រាប់រាជរដ្ឋាភិបាលបានយល់កាន់តែស៊ីជម្រៅបន្ថែមទៀត អំពីទស្សនៈ, តម្រូវការ និងកង្វល់របស់ពួកគេ ។

## ៣- <u>ក្រុមការងារបច្ចេកទេសចម្រុះ</u>

ក្រុមការងារបច្ចេកទេសចម្រុះដែលបានបង្កើតឡើងក្នុងឆ្នាំ ២០០៤ នៅតែជាយន្តការមានប្រសិទ្ធភាពសម្រាប់ពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ។ ថ្វីត្បិតយន្តការនេះត្រូវបាន

គាំទ្រដោយ ក.អ.ក/គ.ជ.នា ប៉ុន្តែ កិច្ចដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់ក្រសួងនិងស្ថាប័នសាមី និងគាំទ្រដោយអ្នកសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ។ សមត្ថភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះមានការវិវត្តឈានឡើង ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ដោយផ្អែកលើបរិការណ៍ប្រែប្រួល, សមត្ថភាព និងតម្រូវការរបស់វិស័យនីមួយៗ ។

ដើម្បីវាយតម្លៃសមិទ្ធកម្ម និងស័ក្តិសិទ្ធិភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ក.អ.ក/គ.ជ.នា បានធ្វើអង្កេតលើក្រុមការងារទាំងនេះ ក្នុងត្រីមាសទី ៣ ឆ្នាំ ២០១៨ ។ ក.អ.ក/គ.ជ.នា បានទទួលចម្លើយ ៣០ ពីក្រុមការងារទាំង ១៩ (ចម្លើយមួយចំនួនត្រូវបានបំពេញរួមគ្នាដោយស្ថាប័ននៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍, រីឯចម្លើយមួយចំនួនទៀតជាការបំពេញដាច់ដោយឡែកៗពីគ្នា) ។ លទ្ធផលបង្ហាញថា ÷

- ក្រុមការងារបច្ចេកទេសចម្រុះភាគច្រើននៅបន្តសកម្មភាពការងារ ។ ក្រុមការងារដែលមានសមិទ្ធកម្មល្អ បានផ្លាស់ប្តូររបៀបរបបការងារ ស្របតាមការប្រែប្រួលបរិការណ៍, បានដោះស្រាយបញ្ហាប្រឈម និងក្តាប់ជាប់នូវកាលានុវត្តភាពរបស់វិស័យ ។
- ក្រុមការងារមួយចំនួនបានដំណើរការល្អ (ពិន្ទុ ៣,៨ លើ ៥ ដែលជារង្វាស់សមិទ្ធកម្មខាងបរិមាណ) ។
- ក្រុមការងារដែលទទួលជោគជ័យភាគច្រើន បានរៀបចំបទដ្ឋានពាក់ព័ន្ធនឹងការប្រជុំទៀងទាត់, ទម្រង់នៃកិច្ចប្រជុំ, សមាជិកភាព និងដែនសមត្ថកិច្ចរបស់ខ្លួន ។
- ក្រុមការងារខ្លះត្រូវពិនិត្យឡើងវិញអំពីគោលបំណង និងសមាជិកភាព ដើម្បីឲ្យស្របទៅនឹងអាទិភាពដែលមានរំលេចក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ។
- ក្រុមការងារភាគច្រើនយល់ថា វិស័យឯកជនបានក្លាយជាតួអង្គអភិវឌ្ឍន៍សំខាន់របស់វិស័យ ប៉ុន្តែតួអង្គនេះមិនមានតំណាងពេញលេញរបស់ខ្លួនក្នុងកិច្ចពិគ្រោះយោបល់ឡើយ ។
- ក្រុមការងារភាគច្រើនដែលបំពេញការងារអន្តរវិស័យ គឺជាក្រុមការងារដែលបានជួបប្រទះបញ្ហាប្រឈមច្រើនជាងគេ ពិសេសពាក់ព័ន្ធនឹងការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការតាមដានអំពីលទ្ធផលការងារ ។

ដើម្បីអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ប្រកបដោយជោគជ័យ ក្រុមការងារបច្ចេកទេសចម្រុះ គឺជាយន្តការសំខាន់សម្រាប់ពិគ្រោះយោបល់កម្រិតបច្ចេកទេស និងសម្រាប់តម្រង់ទិសការធ្វើកម្មវិធីនីយកម្មធនធានរបស់ក្រសួង និងស្ថាប័ន, ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ។ ទោះបីក្រុមការងារបច្ចេកទេសចម្រុះទាំងអស់បានបញ្ជាក់ភាពចាំបាច់ក្នុងការបន្តអនុវត្តសកម្មភាពការងារ ក៏យន្តការនេះត្រូវពិនិត្យវិសាលភាពការងារឡើងវិញ ដើម្បីឆ្លើយតបនឹងអាទិភាពអភិវឌ្ឍន៍ ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។ ក្រុមការងារបច្ចេកទេសភាគច្រើនបានលើកឡើងនូវភាពចាំបាច់នៃការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងសមត្ថភាព និងពង្រឹងការផ្តល់សេវាសាធារណៈ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនៅតែបន្តអនុវត្តភាពទន់ភ្លន់ក្នុងការបង្កើតក្រុមការងារថ្មី ដូចករណីក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការប្រែប្រួលអាកាសធាតុ ដែលបានបង្កើតក្នុងពេលអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ច

សហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូកន្លងមក ។ បញ្ហាសំខាន់ដែលដកស្រង់ចេញពីលទ្ធផលនៃការធ្វើអង្កេតស្តីពីសមិទ្ធកម្មនៃយន្តការក្រុមការងារបច្ចេកទេសចម្រុះ មានដូចខាងក្រោម÷

- ការធានាសង្គតិភាពរវាងអាណត្តិការងារ, សមាជិកភាព និងការគ្រប់គ្រងក្រុមការងារបច្ចេកទេសចម្រុះ ។
- ការតម្រឹមផែនការការងារ និងក្របខណ្ឌលទ្ធផលរបស់ក្រុមការងារបច្ចេកទេសចម្រុះ ជាមួយនឹងអាទិភាពអភិវឌ្ឍន៍ជាតិ ។
- ការបន្តពង្រឹងប្រសិទ្ធភាពនៃយន្តការក្រុមការងារ ដោយធានាតុល្យភាពរវាងការចូលរួមរបស់វិស័យឯកជន, សុខដុមនីយកម្មនៃភាពជាដៃគូ និងការផ្តោតលើលទ្ធផល ។

ជារួម ក្រុមការងារបច្ចេកទេសចម្រុះបានដំណើរការប្រកបដោយប្រសិទ្ធភាព និងមានការវិវត្តល្អប្រសើរ ក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង និងស្ថាប័នសាមី ។ ទោះជាយ៉ាងនេះក្តី ក.អ.ក/គ.ជ.នា នឹងកែសម្រួលសេចក្តីណែនាំរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដោយផ្អែកលើការផ្តល់យោបល់ និងសក្ខីកម្មនៃឧត្តមានុវត្តន៍របស់ក្រុមការងារ ។ សេចក្តីណែនាំនេះនឹងគូសបញ្ជាក់អំពីលក្ខខណ្ឌក្នុងការបង្កើតក្រុមការងារថ្មី និងការរៀបចំឱ្យមានអនុក្រុមការងារ ។ ក.អ.ក/គ.ជ.នា នឹងបន្តរៀបចំកិច្ចប្រជុំនៃបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ក៏ដូចជាផ្តល់កាលានុវត្តភាពសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា ។

## ៤- កិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ

រាជរដ្ឋាភិបាលបានទទួលស្គាល់អំពីភាពចាំបាច់ ក្នុងការលើកកម្ពស់កិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ ។ យន្តការថ្មីប្រកបដោយគំនិតច្នៃប្រឌិតនេះនឹងផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាទូទៅនៃកិច្ចអភិវឌ្ឍន៍ ពិសេសស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ និងបញ្ហាប្រឈមផ្នែកហិរញ្ញប្បទាននៅកម្រិតវិស័យ ។ យន្តការថ្មីនេះក៏ជួយលើកកម្ពស់បរិយាប័ន្ន តាមរយៈការបង្កើនការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ និងបំពេញបន្ថែមឱ្យយន្តការក្រុមការងារបច្ចេកទេសចម្រុះ ព្រមទាំងជំរុញអនុវត្តសូចនាករតាមដានរួមគ្នាឱ្យកាន់តែប្រសើរឡើង ។ យន្តការពិគ្រោះយោបល់ដែលចូលរួមពីតំណាងរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍, អង្គការសង្គមស៊ីវិល, វិស័យឯកជន និងគ្រឹះស្ថានស្រាវជ្រាវនឹងផ្តល់កាលានុវត្តភាពសម្រាប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពនៃកិច្ចអភិវឌ្ឍន៍, បញ្ហាប្រឈមរបស់វិស័យ ព្រមទាំងកំណត់ទស្សនទានរួមសម្រាប់រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលតម្រូវឱ្យអនុវត្តរួមគ្នា និងដាច់ដោយឡែកពីគ្នា រួមទាំងកំណត់ប្រភពធនធានសម្រាប់គាំទ្រ ។ កិច្ចពិគ្រោះយោបល់នេះនឹងត្រូវរៀបចំជាទៀងរាល់ឆ្នាំ ឬតាមការចាំបាច់ ក្រោមការដឹកនាំរបស់ក្រសួង និងស្ថាប័នសាមី ដោយមានកិច្ចសហការជាមួយ ក.អ.ក/គ.ជ.នា ដែលជាស្ថាប័នសម្របសម្រួលរបស់រាជរដ្ឋាភិបាល ។

## ៥- កិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល

រាជរដ្ឋាភិបាលទទួលស្គាល់អំពីសារៈសំខាន់នៃការបន្តរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងកិច្ចអភិវឌ្ឍន៍ជាតិ តាមរយៈការកៀរគរហិរញ្ញប្បទាន ក៏ដូចជាការធ្វើការងារជាមួយដៃគូក្នុងប្រទេស ក្នុងការផ្តល់សេវាសាធារណៈ ពិសេសក្នុងវិស័យសង្គមកិច្ច ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តយន្តការពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើនជំនឿទុកចិត្តទៅវិញទៅមក, លើកកម្ពស់តម្លាភាព និងគណនេយ្យភាព ក៏ដូចជាចែក

រំលែកព័ត៌មាន ពិសេសព័ត៌មានពាក់ព័ន្ធនឹងវឌ្ឍនភាព, បញ្ហាប្រឈម និងដំណោះស្រាយ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។ គោលបំណងចម្បងនៃការបន្តកិច្ចសហការនាពេលអនាគត គឺដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី៤, ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ក៏ដូចជាយុទ្ធសាស្រ្តតាមវិស័យ និងការកែទម្រង់របស់រាជរដ្ឋាភិបាល ។

### ៦- កិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី-ខេត្ត

រាជរដ្ឋាភិបាលបាន និងបន្តលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញ និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ និងដោះស្រាយគំលាតនៃការអភិវឌ្ឍនៅមូលដ្ឋាន តាមរយៈការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ រដ្ឋបាលថ្នាក់ក្រោមជាតិបានដើរតួនាទីសំខាន់ ដើម្បីរួមចំណែកអនុវត្តឱ្យបានសម្រេចនូវទិសដៅអាទិភាពជាតិ ក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលនឹងដាក់ឱ្យដំណើរការនូវយន្តការពិគ្រោះយោបល់នៅថ្នាក់រាជធានី-ខេត្ត សម្រាប់លើកកម្ពស់បរិយាប័ន្ននៃការចូលរួមរបស់តួអង្គអភិវឌ្ឍន៍ទាំងអស់ (ដៃគូអភិវឌ្ឍន៍, អង្គការសង្គមស៊ីវិល, សហគមន៍មូលដ្ឋាន និងវិស័យឯកជន) ក្រោមការដឹកនាំរបស់រដ្ឋបាលរាជធានី-ខេត្ត ។ យន្តការនេះមានទិសដៅលើកកម្ពស់អភិក្រមនៃការចូលរួម និងពង្រឹងគុណភាពសេវាសាធារណៈនៅថ្នាក់ក្រោមជាតិ ។ យន្តការពិគ្រោះយោបល់នេះអាចរៀបចំ ២ដងក្នុងមួយឆ្នាំ ឬតាមការចាំបាច់ ដើម្បីផ្តល់កាលានុវត្តភាព សម្រាប់ពិភាក្សាអំពីវឌ្ឍនភាពនៃកិច្ចអភិវឌ្ឍន៍, បញ្ហាប្រឈម និងកំណត់វិធានការចាំបាច់នានា ។ ក.អ.ក/គ.ជ.ទា និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងផ្តល់ការគាំទ្រសម្រាប់ចាប់ផ្តើមដំណើរការយន្តការពិគ្រោះយោបល់នេះ ដោយផ្អែកតាមសំណើ និងអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ ដៃគូអភិវឌ្ឍន៍, អង្គការសង្គមស៊ីវិល និងវិស័យឯកជននៅថ្នាក់ក្រោមជាតិ ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងយន្តការពិគ្រោះយោបល់នេះ ។

### ៧- ការរៀបចំសេចក្តីណែនាំស្តីពីភាពជាដៃគូ និងការអនុវត្ត

សេចក្តីណែនាំស្តីពីភាពជាដៃគូ នឹងត្រូវរៀបចំ ដើម្បីបញ្ជាក់អំពីទិសដៅ, ទម្រង់ និងការគ្រប់គ្រងភាពជាដៃគូ និងការពិគ្រោះយោបល់ ។ ការរៀបចំសេចក្តីណែនាំទាំងនេះត្រូវផ្អែកលើគោលការណ៍ដែលមានចែងក្នុងយុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ និងបន្ទាប់មក ត្រូវពិភាក្សា និងឯកភាពជាមួយនឹងតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធ ។ គោលដៅចម្បងនៃសេចក្តីណែនាំ គឺការផ្តល់ការគាំទ្រដល់យន្តការពិគ្រោះយោបល់ថ្មីទាំងនេះ និងត្រូវពិនិត្យ និងកែសម្រួលឡើងវិញ ក្នុងករណីចាំបាច់ តាមរយៈរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តយុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។

### ៨- សូចនាករតាមដានរួមគ្នា

ក្រុមការងារបច្ចេកទេសចម្រុះភាគច្រើនបានអនុវត្តសូចនាករតាមដានរួមគ្នារបស់ខ្លួនប្រកបដោយជោគជ័យ ។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តថវិកាកម្មវិធីផ្តោតលើលទ្ធផល ដែលសម្រេចវឌ្ឍនភាពល្អប្រសើរ បានផ្តល់កាលានុវត្តភាព សម្រាប់ពង្រឹងដំណើរការរៀបចំសូចនាករតាមដានរួមគ្នា ដោយត្រូវផ្សារភ្ជាប់ឱ្យកាន់តែជិតស្និទ្ធថែមទៀត ជាមួយនឹងដំណើរការរៀបចំថវិកាជាតិ ។ ក្នុងន័យនេះ យន្តការក្រុមការងារបច្ចេកទេសចម្រុះបានក្លាយ

ជាវេទិកាសម្រាប់ពិភាក្សា, កំណត់អាទិភាព និងតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងអាទិភាពទាំងនេះ ព្រមទាំងកំណត់ទិសដៅ និងចំណុចដៅសំខាន់ៗ ។

លើមូលដ្ឋាននេះ សូចនាករតាមដានរួមគ្នានឹងត្រូវបន្តអនុវត្ត ហើយអភិក្រមសម្រាប់កំណត់លទ្ធផលរយៈពេល ៥ ឆ្នាំ ដែលជាមូលដ្ឋានសម្រាប់កំណត់ធាតុចេញរយៈពេល ១-៣ ឆ្នាំ របស់សូចនាករនីមួយៗ នៅតែរក្សាភាពសមស្របរបស់ខ្លួន ។ ទោះជាយ៉ាងនេះក្តី ក៏ទម្រង់ និងដំណើរការរៀបចំសូចនាករទាំងនេះនឹងត្រូវកែសម្រួល ក្នុងគោលដៅតម្រឹមជាមួយនឹងដំណើរការរៀបចំថវិការដ្ឋ ។ ក្នុងន័យនេះ សូចនាករតាមដានរួមគ្នាត្រូវបានរៀបចំ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការ ឬគោលនយោបាយតាមវិស័យ ហើយត្រូវផ្សារភ្ជាប់នឹងកម្មវិធីនីយកម្ម និងថវិកានីយកម្ម ក្នុងពេលដែលថវិកាព័តិមានសមិទ្ធកម្មកំពុងត្រូវបានបន្តអនុវត្ត ។

## ៩- របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ

ក.អ.ក/គ.ជ.នា នឹងតាមដានជារៀងរាល់ឆ្នាំ នូវការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ តាមរយៈការរៀបចំរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដោយផ្តោតលើ ÷

- ការពិនិត្យសមិទ្ធកម្ម ,ការវិភាគវឌ្ឍនភាព និងបទពិសោធន៍របស់ក្រុមការងារបច្ចេកទេសចម្រុះ
- ការត្រួតពិនិត្យការអនុវត្តសូចនាករតាមដានរួមគ្នា (រួមទាំងការត្រួតពិនិត្យកិច្ចដំណើរការ ដើម្បីធានាភាពសមស្រប និងលទ្ធផល)
- ការវិភាគអំពីការវិវត្តនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល, ការគាំទ្រហិរញ្ញប្បទានតាមវិស័យ និងការតម្រឹមជាមួយអាទិភាពជាតិ
- ការពិនិត្យវឌ្ឍនភាពក្នុងការអនុវត្តការប្តេជ្ញាសកលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា (រួមទាំងលទ្ធផលនៃការអង្កេតការប្តេជ្ញាទីក្រុងប៊ូសាន)
- ត្រួតពិនិត្យសកម្មភាពនៃយន្តការពិគ្រោះយោបល់ និងការអនុវត្តសេចក្តីណែនាំស្តីពីភាពជាដៃគូ
- ការធ្វើបច្ចុប្បន្នភាពហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (សម្រាប់ជាធាតុចូលក្នុងការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

## ១០- ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាល

ក.អ.ក/គ.ជ.នា បានបង្កើត និងគ្រប់គ្រងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ប្រព័ន្ធទិន្នន័យទាំងពីរនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ តាមរយៈគេហទំព័រ www.odacambodia.com ដើម្បីលើកកម្ពស់តម្លាភាពនៃការប្រើប្រាស់ហិរញ្ញប្បទាន និងសម្រាប់រៀបចំកម្មវិធីនីយកម្ម និងការសម្របសម្រួល ។

តួនាទីនៃប្រព័ន្ធទិន្នន័យទាំងនេះ សម្រាប់គាំទ្រការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ មានដូចខាងក្រោម ÷

## សូចនាករស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍តាមដៃគូអភិវឌ្ឍន៍នីមួយៗ

| | ការប្រើប្រាស់ក្របខណ្ឌលទ្ធផល (%) | | ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (%) | | ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ (%) | | ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ (%) | | ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានប្រចាំឆ្នាំ (%) | | ផែនការប្រចាំឆ្នាំផ្តល់ឱ្យប្រទេសដៃគូ | | ផែនការ ៣ ឆ្នាំផ្តល់ឱ្យប្រទេសដៃគូ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2015 | 2017 | 2015 | 2017 | 2015 | 2017 | 2015 | 2017 | 2015 | 2017 | 2015 | 2017 | 2015 | 2017 |
| UN Agencies | | | | | | | | | | | | | | |
| FAO | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 24 | 0 | Yes | Yes | No | No |
| ILO | 0 | 0 | 0 | 0 | 0 | 0 | 100 | 0 | 100 | 0 | Yes | Yes | No | No |
| UN Women | 0 | 100 | 0 | 0 | 0 | 0 | 0 | 0 | 6 | 0 | Yes | No | No | No |
| UN AIDS | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 71 | 0 | Yes | No | No | No |
| UNDP | 67 | 100 | 3 | 0 | 0 | 0 | 0 | 0 | 100 | 100 | Yes | Yes | Yes | Yes |
| UNESCO | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | No | No | No |
| UNFPA | 0 | 0 | 0 | 0 | 0 | 0 | 100 | 0 | 100 | 100 | Yes | No | No | No |
| UNICEF | 0 | 100 | 0 | 0 | 0 | 0 | 0 | 0 | 100 | 78 | Yes | Yes | No | No |
| UNIDO | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 100 | 0 | Yes | Yes | Yes | Yes |
| WFP | 0 | 0 | 0 | 0 | 0 | 0 | 100 | 0 | 100 | 0 | Yes | No | No | No |
| WHO | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 100 | 60 | Yes | Yes | No | No |
| IFAD | 99 | 100 | 4 | 60 | 6 | 88 | 100 | 100 | 100 | 100 | Yes | Yes | Yes | Yes |
| Multilateral | | | | | | | | | | | | | | |
| ADB | 86 | 100 | 97 | 94 | 97 | 94 | 94 | 99 | 41 | 57 | Yes | Yes | Yes | Yes |
| World Bank | 100 | 100 | 33 | 45 | 100 | 98 | 90 | 70 | 100 | 75 | Yes | Yes | Yes | Yes |
| Global Fund | 68 | 0 | 0 | 0 | 0 | 0 | 100 | 0 | 100 | 100 | Yes | No | No | No |
| GAVI | 0 | 0 | 0 | 0 | 0 | 0 | 100 | 0 | 100 | 100 | Yes | Yes | Yes | No |
| European Union | | | | | | | | | | | | | | |
| EU/EC | 65 | 86 | 38 | 65 | 62 | 65 | 62 | 88 | 83 | 100 | Yes | Yes | Yes | Yes |
| Czech Rep | 0 | 0 | 0 | 0 | 0 | 0 | 100 | 0 | 100 | 0 | Yes | No | No | No |
| France | 11 | 100 | 36 | 91 | 38 | 91 | 62 | 51 | 57 | 100 | Yes | Yes | No | Yes |
| Germany | 44 | 100 | 4 | 46 | 0 | 43 | 33 | 13 | 100 | 100 | Yes | Yes | Yes | Yes |
| Ireland | 0 | 75 | 0 | 0 | 0 | 0 | 100 | 0 | 100 | 0 | No | Yes | No | No |
| Sweden | 36 | 69 | 47 | 56 | 47 | 96 | 0 | 0 | 73 | 100 | Yes | Yes | Yes | Yes |
| UK | 0 | 0 | 0 | 0 | 0 | 0 | 100 | 0 | 100 | 0 | Yes | Yes | No | No |
| Bilateral | | | | | | | | | | | | | | |
| Australia | 83 | 0 | 0 | 0 | 0 | 0 | 4 | 0 | 100 | 100 | Yes | Yes | Yes | Yes |
| Canada | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 11 | 0 | Yes | Yes | Yes | Yes |
| China | 0 | 0 | 99 | 96 | 0 | 0 | 100 | 100 | 100 | 100 | Yes | Yes | Yes | Yes |
| Japan | 57 | 98 | 28 | 40 | 28 | 40 | 89 | 93 | 100 | 100 | Yes | Yes | Yes | Yes |
| New Zealand | 60 | 0 | 0 | 0 | 0 | 0 | 0 | 0 | 100 | 0 | Yes | Yes | Yes | Yes |
| Rep of Korea | 32 | 33 | 53 | 56 | 15 | 6 | 46 | 70 | 84 | 88 | Yes | Yes | Yes | Yes |
| Switzerland | 59 | 57 | 27 | 48 | 27 | 48 | 100 | 0 | 100 | 100 | Yes | Yes | Yes | Yes |
| USA | 0 | 0 | 0 | 0 | 1 | 0 | 100 | 0 | 100 | 100 | Yes | Yes | Yes | Yes |
| **Total** | **37** | **64** | **57** | **76** | **26** | **44** | **79** | **83** | **87** | **96** | **99** | **95** | **95** | **93** |

ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យរដ្ឋ ឆ្នាំ២០១៥: វិស័យរដ្ឋរួមមានក្រសួង-ស្ថាប័ន, រដ្ឋបាលថ្នាក់ក្រោមជាតិ, វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះហត្ថលេខាកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល ។

ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យសាធារណៈ ឆ្នាំ២០១៧ : វិស័យសាធារណៈរួមមានស្ថាប័ន និងអង្គភាពរដ្ឋ ដោយមិនរាប់បញ្ចូលអង្គការសង្គមស៊ីវិល, វិស័យឯកជន និងតួអង្គមិនមែនរដ្ឋ ។

ប្រភពទិន្នន័យ : ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការរបស់ ក.អ.ក/គ.ជ.នា

- កត់ត្រាការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរហូតដល់ពេលបច្ចុប្បន្ន និងផែនការបើកផ្តល់ (រួមទាំងការប៉ាន់ស្មានការបើកផ្តល់ហិរញ្ញប្បទានសម្រាប់រយៈពេល ៣ឆ្នាំខាងមុខ)
- ផ្តល់លទ្ធភាពសម្រាប់ពិនិត្យព័ត៌មានពាក់ព័ន្ធនឹងគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍
- រៀបចំទម្រង់របាយការណ៍តាមតម្រូវការរបស់អ្នកប្រើប្រាស់ និងទាញយកទិន្នន័យហិរញ្ញប្បទាន សម្រាប់វិភាគក្នុងប្រព័ន្ធ Excel
- កត់ត្រាវឌ្ឍនភាពនៃការអនុវត្តសូចនាករទីក្រុងប៊ូសាន (ក្របខណ្ឌលទ្ធផល និងការប្រើប្រាស់ប្រព័ន្ធជាតិ)
- វិភាគអំពីការគាំទ្រអន្តរវិស័យ ដូចជាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ
- វិភាគហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់គាំទ្រការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។

របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ បានវិភាគអំពីការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងអាទិភាពអភិវឌ្ឍន៍ជាតិ ។ លើសពីនេះ ស្របតាមការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, របាយការណ៍នេះមានតួនាទីសំខាន់ ក្នុងការសម្របសម្រួល និងការរៀបចំកម្មវិធីនីយកម្មនៃធនធានក្រៅប្រទេស ដោយសារធនធានទាំងនេះនឹងត្រូវបញ្ចូលកាន់តែច្រើនឡើងៗ ទៅក្នុងថវិការដ្ឋ ។

**១១- <u>ភាពជាដៃគូសកលសម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងការអង្កេតការប្តេជ្ញាទីក្រុងប៊ូសាន</u>**

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានបញ្ជាក់អំពីការបន្តចូលរួមយ៉ាងសកម្មរបស់កម្ពុជា ក្នុងភាពជាដៃគូសកលសម្រាប់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ដែលត្រូវបានប្រកាសក្នុងឆ្នាំ ២០១១ នៅទីក្រុងប៊ូសាននៃសាធារណរដ្ឋកូរ៉េ ។

ភាពជាដៃគូសកលដែលបានកំណត់គោលការណ៍មួយចំនួន ដូចជា ភាពជាម្ចាស់, ការផ្តោតលើលទ្ធផល, ភាពជាដៃគូសកលប្រកបដោយបរិយាប័ន្ន និងតម្លាភាព ត្រូវបានរំលេចក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ គោលការណ៍ខាងលើគឺជាមូលដ្ឋានសម្រាប់ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ ។ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នឹងបន្តចូលរួមការធ្វើអង្កេតស្តីពីការអនុវត្តការប្តេជ្ញាទីក្រុងប៊ូសាន និងរួមគ្នាអនុវត្តគំនិតផ្តួចផ្តើមថ្មីៗ ស្របតាមបរិការណ៍កម្ពុជា ដោយផ្អែកលើលទ្ធភាពធនធាន និងសមត្ថភាព ។

## គ- យន្តការស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រ

ក្រសួងនិងស្ថាប័ននីមួយៗ មានតួនាទីសំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដោយសារយុទ្ធសាស្ត្រនេះគឺជាក្របខណ្ឌសម្រាប់លើកកម្ពស់ និងគ្រប់គ្រងភាពជាដៃគូ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ។ ផ្អែកលើសមិទ្ធផលដែលបានសម្រេចក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ ទន្ទឹមនឹងភាពជោគជ័យនៃការកែទម្រង់ប្រព័ន្ធផែនការ និងថវិការដ្ឋ, យន្តការស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ មានដូចខាងក្រោម ÷

១-ក.អ.ក/គ.ជ.នា បន្តអនុវត្តតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាល និងជាស្ថាប័នសម្របសម្រួលការដឹកនាំ កៀរគរ និងគ្រប់គ្រងធនធានសហប្រតិបត្តិការ ។ ទន្ទឹមនឹងនេះ ក៏ជាចំណុចប្រមូលផ្តុំ ដើម្បីពិភាក្សាជាមួយ ដៃគូអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានឥតសំណង សម្រាប់រៀបចំកម្មវិធី, តាមដាន និងវាយតម្លៃការប្រើប្រាស់ ហិរញ្ញប្បទាននេះ ។ ក្នុងន័យនេះ ក.អ.ក/គ.ជ.នា អាចផ្តល់ការគាំទ្រដូចខាងក្រោម ÷

- រៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានឥតសំណង និង កិច្ចប្រជុំនៃបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ ។
- តាមដានស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ តាមរយៈការរៀបចំ និងការត្រួតពិនិត្យការអនុវត្តសូចនាករ តាមដានរួមគ្នា និងចូលរួមក្នុងកិច្ចការស្តីពីភាពជាដៃគូសកល ព្រមទាំងការធ្វើអង្កេតទីក្រុងប៊ូសាន ។
- វាយតម្លៃ និងផ្តល់ការឯកភាពលើគម្រោងហិរញ្ញប្បទានឥតសំណង និងចូលរួមតាមដានការ អនុវត្តគម្រោងតាមការជាក់ស្តែង ។
- គ្រប់គ្រងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែន-រដ្ឋាភិបាល ។
- ផ្តល់ការគាំទ្រតាមតម្រូវការ ដល់ក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល និងសម្របសម្រួលការងារ ពាក់ព័ន្ធនឹងភាពជាដៃគូ និងស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។

២-គណៈកម្មាធិការវិនិយោគកម្ពុជា បំពេញតួនាទីជាអគ្គលេខាធិការដ្ឋាននៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន និងសម្របសម្រួលកិច្ចប្រជុំទាំងនេះ ដោយមានការពិគ្រោះយោបល់ជាមួយនឹងក្រុមការងារផ្នែកឯកជន ។

៣-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ។ ទន្ទឹមនឹងនេះ ផ្អែកលើធាតុចូលរបស់ ក.អ.ក/គ.ជ.នា និងតម្រូវការហិរញ្ញប្បទានក្រៅប្រទេសដែលមានចែងក្នុងកម្មវិធីវិនិយោគសាធារណៈ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំណត់តម្រូវការហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន សម្រាប់ អនុវត្តកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ ទន្ទឹមនឹងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពនៃ បំណុល ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាតំណាងរបស់រាជរដ្ឋាភិបាលតែមួយគត់ ដែលមានសិទ្ធិចុះ ហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាន និងគ្រប់គ្រងគម្រោងឥណទានសម្បទាន គិតចាប់តាំងពី ដំណាក់កាលរៀបចំ និងវាយតម្លៃគម្រោង រហូតដល់ការតាមដានការអនុវត្តគម្រោង ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ដែលជាផ្នែកមួយនៃការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម សម្រាប់តាមដានវឌ្ឍនភាពនៃការ អនុវត្តអាទិភាពនានាដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ។

៤-ក្រសួងផែនការរៀបចំ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សម្រាប់តម្រង់ការវិនិយោគ សាធារណៈ និងតម្រឹមការវិភាជធនធានសហប្រតិបត្តិការជាមួយនឹងអាទិភាពជាតិ ។ ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិនឹងបញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ទៅក្នុងក្របខណ្ឌផែនការជាតិតែមួយ

និងពិនិត្យបញ្ហានានាដែលពាក់ព័ន្ធនឹងហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ ។ លើសពីនេះ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងរំលេចអំពីវឌ្ឍនភាព និងប្រមូលទិន្នន័យ ដើម្បីបូកសរុបគ្រប់ជ្រុងជ្រោយ អំពីសមិទ្ធផល និងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា សម្រាប់ជាមូលដ្ឋានក្នុងការកំណត់សកម្មភាពដែលត្រូវបន្តអនុវត្តនាពេលខាងមុខ ។ លើសពីនេះ ដោយសហការជាមួយ ក.អ.ក/គ.ជ.នា និងក្រសួងនិងស្ថាប័ន, ក្រសួងផែនការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ដើម្បីកំណត់គម្រោងអាទិភាព ដោយផ្អែកលើព័ត៌មានដែលបានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងធាតុចូលរបស់ក្រសួងនិងស្ថាប័ន ។

៥-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបំពេញតួនាទីជាច្រកទ្វារការទូត ក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ក.អ.ក/គ.ជ.នា ទទួលខុសត្រូវរៀបចំកម្មវិធីសហប្រតិបត្តិការ និងចរចាគម្រោងហិរញ្ញប្បទានឥតសំណង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រប់គ្រងកិច្ចព្រមព្រៀងឥណទានសម្បទាន ។

៦- ក្រសួងនិងស្ថាប័នពាក់ព័ន្ធមានតួនាទីដឹកនាំក្រុមការងារបច្ចេកទេសចម្រុះ និងចាត់តាំងមន្ត្រីជាន់ខ្ពស់ឲ្យចូលរួមក្នុងក្រុមការងារនេះ ស្របតាមអាណត្តិនៃស្ថាប័នរបស់ខ្លួន ។ ក្រសួងដែលដឹកនាំក្រុមការងារបច្ចេកទេសចម្រុះ ត្រូវរៀបចំសូចនាករតាមដានរួមគ្នា និងតាមដានការអនុវត្តសូចនាករទាំងនេះ ។ ដោយសហការជាមួយ ក.អ.ក/គ.ជ.នា និងក្រសួងផែនការ, ក្រសួងនិងស្ថាប័នត្រូវត្រួតពិនិត្យព័ត៌មានទាំងឡាយដែលបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាល សម្រាប់ជាធាតុចូលក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ ។ ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការដាក់បញ្ចូលហិរញ្ញប្បទានសហប្រតិបត្តិការទៅក្នុងថវិការដ្ឋ និងការដាក់បញ្ចូលគ្នារវាងថវិកាមូលធននិងថវិកាចរន្ត តម្រូវឲ្យក្រសួងនិងស្ថាប័នធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីសម្របសម្រួល និងពង្រឹងភាពជាដៃគូ សម្រាប់តម្រឹមការផ្តល់ធនធានជាមួយនឹងអាទិភាពជាតិ ។

៧-ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវពិនិត្យកម្មវិធីឡើងវិញ ដើម្បីធានាសង្គតិភាពជាមួយយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។ រាជរដ្ឋាភិបាលជំរុញដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមឲ្យបានពេញលេញក្នុងយន្តការភាពជាដៃគូ និងកិច្ចពិគ្រោះយោបល់ ដូចជាក្រុមការងារបច្ចេកទេសចម្រុះ និងកិច្ចពិគ្រោះយោបល់ទ្វេភាគី ។ រាជរដ្ឋាភិបាលសូមស្វាគមន៍ចំពោះធាតុចូលរបស់តួអង្គអភិវឌ្ឍន៍ទាំងអស់ដែលបានលើកឡើងក្នុងកិច្ចពិគ្រោះយោបល់ សម្រាប់ជាមូលដ្ឋានកំណត់អាទិភាព, រៀបចំថវិកា និងសូចនាករតាមដានរួមគ្នា ។ លើសពីនេះ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលគប្បីពិនិត្យរបៀបរបបអនុវត្តការងាររបស់ខ្លួនឡើងវិញ ដោយផ្អែកលើគោលការណ៍ស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ និងភាពជាដៃគូសកល ទន្ទឹមនឹងការបន្តចូលរួមក្នុងការធ្វើអង្កេតស្តីពីការអនុវត្តការប្តេជ្ញាទីក្រុងប៊ូសាន ។

យន្តការស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ត្រូវបានរៀបចំ

ដើម្បីផ្តល់កាលានុវត្តភាពឲ្យកាន់តែច្រើន សម្រាប់លើកកម្ពស់ភាពជាដៃគូដោយផ្តោតលើលទ្ធផល ។ តាមរយៈការអនុវត្តគោលការណ៍ដែលមានចែងក្នុងផ្នែក "ក" នៃជំពូកនេះ, ហានិភ័យនឹងអាចកាត់បន្ថយ ដោយសារបានកំណត់ច្បាស់អំពី "វិធាននៃល្បែង" ។ លើមូលដ្ឋាននេះ ហានិភ័យនឹងត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តាមរយៈការកំណត់ឧបករណ៍ច្បាស់លាស់ និងការបង្កើតកាលានុវត្តភាពសម្រាប់ពិគ្រោះយោបល់ និងតាមដានរួមគ្នាលើភាពជាដៃគូ និងលទ្ធផលដែលបានសម្រេច ។

## V. ភាពជាដៃគូសម្រាប់គាំទ្រលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍

ទន្ទឹមនឹងវឌ្ឍនភាពដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងកម្មវិធីកែទម្រង់នានា ពិសេសការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងថវិកា និងក្នុងពេលដែលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ត្រូវបានធ្វើសមាហរណកម្មក្នុងផែនការជាតិ និងក្របខណ្ឌតាមដាន, យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូបានកំណត់កាលានុវត្តភាពនៃការកសាងភាពជាដៃគូ ទន្ទឹមនឹងការរំលេចឲ្យឃើញនូវការទទួលខុសត្រូវថ្មីៗផងដែរ ។

យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដែលកំណត់តួនាទីរបស់ ក.អ.ក/គ.ជ.នា ជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល បានឆ្លុះបញ្ចាំងអំពីការទទួលខុសត្រូវស្នូលរបស់ស្ថាប័ននេះក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ដោយសារការអភិវឌ្ឍកម្ពុជាបានបោះជំហានទៅមុខយ៉ាងឆាប់រហ័ស, យុទ្ធសាស្ត្រនេះបានទទួលស្គាល់អំពីតម្រូវការក្នុងការពង្រីកវិសាលភាពនៃភាពជាដៃគូបន្ថែមទៀត ក្រៅពីភាពជាដៃគូដែលមានស្រាប់ជាមួយដៃគូអភិវឌ្ឍន៍ ។ ក្នុងន័យនេះ ទោះបីយុទ្ធសាស្ត្រនេះបានបន្តយកចិត្តទុកដាក់លើការគ្រប់គ្រងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគី, ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ, ក៏យុទ្ធសាស្ត្រនេះបានរៀបចំគោលការណ៍ណែនាំបន្ថែម សម្រាប់ពង្រឹងភាពជាដៃគូជាមួយតួអង្គដទៃទៀត រួមទាំងដៃគូក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងវិស័យឯកជន និងផ្សារភ្ជាប់ធនធានទាំងនេះទៅនឹងថវិការដ្ឋ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើ ÷ ក) តួនាទីចម្បងនៃធនធានក្នុងប្រទេសផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ជាតិ, ខ) ការរៀបចំឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ដែលអាចនាំឲ្យធ្លាក់ចុះនៃហិរញ្ញប្បទានសហប្រតិបត្តិការ (ទាំងទំហំធនធាន ទាំងផលធៀបនឹង ផ.ស.ស) និងការកើនឡើងនៃឥណទានសម្បទាន និង គ) តួនាទីនៃធនធានសហប្រតិបត្តិការ សម្រាប់កសាងភាពជាដៃគូជាមួយនឹងតួអង្គមិនមែនរដ្ឋ ដើម្បីប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការទាំងនេះ សម្រាប់កៀរគរធនធានពីវិស័យសាធារណៈ និងឯកជន ។

### ១- ការកសាងភាពជាដៃគូជុំវិញការរៀបចំថវិការដ្ឋ

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានបញ្ជាក់អំពីតួនាទីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការតាមដានសមិទ្ធកម្មនៃកិច្ចអភិវឌ្ឍន៍ តាមរយៈប្រព័ន្ធថវិកា ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ត្រូវបានបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយត្រូវតាមដានតាមរយៈការអនុវត្តផែនការនេះ ។ ក្នុងន័យនេះ ក្រសួងផែនការនឹងធ្វើរបាយការណ៍បូកសរុបស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផ្តល់ទស្សនវិស័យសម្រាប់អនាគត ។

ក្នុងក្របខណ្ឌនៃថវិការដ្ឋ, ដើម្បីហិរញ្ញប្បទានសហប្រតិបត្តិការអាចបង្កើនលទ្ធភាពកៀរគរធនធានប្រកបដោយប្រសិទ្ធភាព, ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ក្នុងពេលរៀបចំថវិការដ្ឋ ។ អនុវត្តបែបនេះ ទើបហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍អាចរំលេចទៅក្នុងផែនការ និងថវិការបស់ក្រសួង និងស្ថាប័ន ព្រមទាំងផ្តល់លទ្ធភាពក្នុងការពិនិត្យធនធានក្នុងប្រទេស សម្រាប់បំពេញឱ្យហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីអនុវត្តគម្រោង និងកម្មវិធី ។

ក្នុងពេលដៃគូអភិវឌ្ឍន៍ធ្វើការបានជិតស្និទ្ធជាងមុន ក្នុងរយៈពេលរៀបចំថវិការដ្ឋ, ការអនុវត្តថវិកាព័តិមានសមិទ្ធកម្មអាចពង្រឹងភាពជាដៃគូ ដើម្បី÷

- ធានាការតម្រឹមផ្នែកគោលនយោបាយរវាងបណ្តាវិស័យទាំងអស់
- លើកកម្ពស់ការតម្រឹមរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- កំណត់កាលានុវត្តភាព ដើម្បីហិរញ្ញប្បទានសហប្រតិបត្តិការអាចបំពេញតួនាទីក្នុងការបង្កើនលទ្ធភាពកៀរគរ និងតួនាទីជាកាលីករ
- តាមដានលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។

ក្នុងពេលថវិកាបានក្លាយជាឧបករណ៍សំខាន់សម្រាប់លើកកម្ពស់លទ្ធផល និងស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាបានកំណត់ថា ទិសដៅនៃការអនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្ម គឺជាចក្ខុវិស័យរួមរបស់កម្ពុជា ហើយអាចសម្រេចទៅបាន លុះត្រាតែភាគីពាក់ព័ន្ធផ្តល់ការគាំទ្រ និងអនុវត្តដោយស៊ីសង្វាក់គ្នា ។

> **តួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការ :**
> **ការបង្កើនលទ្ធភាពកៀរគរ, កាតាលីករ និងកម្លាំងពន្លឿន**
>
> ក្នុងបរិការណ៍នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, វាក្យស័ព្ទដូចជា**ការបង្កើនលទ្ធភាពកៀរគរ, កាតាលីករ និងកម្លាំងពន្លឿន** ត្រូវបានប្រើប្រាស់ជាញឹកញាប់ ។ រាជរដ្ឋាភិបាលកំណត់និយមន័យនៃវាក្យស័ព្ទទាំងនេះ ដូចខាងក្រោម÷
>
> “**ការបង្កើនលទ្ធភាពកៀរគរ** ” សំដៅដល់ការប្រើប្រាស់ការវិនិយោគមួយ ដើម្បីកៀរគរ ឬទាក់ទាញហិរញ្ញប្បទានបន្ថែម ។ ការបង្កើនលទ្ធភាពកៀរគរនេះអាចធ្វើឡើងដោយផ្ទាល់ តាមរយៈការផ្តល់ធនធានបន្ថែមដល់គម្រោងផ្ទាល់ ក្នុងទម្រង់សហហិរញ្ញប្បទាន ឬដោយប្រយោល ដោយការវិនិយោគរបស់ភាគីមួយ បានជំរុញឱ្យមានការវិនិយោគពីភាគីមួយទៀត ដែលបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ។ ក្នុងបរិបទនៃធនធានរបស់រាជរដ្ឋាភិបាល, ការបង្កើនលទ្ធភាពកៀរគរនៃធនធានអាចធ្វើឡើងតាមរយៈការផ្តល់ថវិកាបដិភាគសម្រាប់គម្រោងរបស់ដៃគូ ឬតាមរយៈការបង្ហាញលទ្ធផលនៃគម្រោង ដែលអាចជះឥទ្ធិពលក្នុងការវិភាជថវិការដ្ឋ, ដូចជាគម្រោងកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ ក្នុងបរិបទនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, គម្រោងរបស់ដៃគូអភិវឌ្ឍន៍អាចបង្កើនការចូលរួមរបស់វិស័យឯកជន ដោយផ្តល់ធនធានដោយផ្ទាល់ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ឬការបង្កើនការវិនិយោគឯកជន ដោយសារធនធានសាធារណៈបានបង្កើតបរិយាកាសអំណោយផលដល់ការវិនិយោគឯកជន ។
>
> វាក្យស័ព្ទ “**កាតាលីករ និងកម្លាំងពន្លឿន**” អាចប្រើជំនួសគ្នាបាន ដើម្បីរៀបរាប់អំពីលទ្ធភាពនៃការវិនិយោគមួយ ដែលអាចជះឥទ្ធិពលអភិវឌ្ឍន៍វែងជាង ឬទូលំទូលាយជាងការប៉ាន់ស្មានដំបូង ។ ឧទាហរណ៍ អាហារូបត្ថម្ភសម្រាប់កុមារតូច បានផ្តល់អត្ថប្រយោជន៍ពេញមួយជីវិត ពិសេសពាក់ព័ន្ធនឹងការរៀនសូត្រ, ការចិញ្ចឹមជីវិត និងការលើកកម្ពស់សមភាពយេនឌ័រ និងការសិក្សា ។ រីឯការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធវិញ អាចជះឥទ្ធិពលដល់សុខភាពមាតា តាមរយៈការបង្កើនលទ្ធភាពទទួល និងប្រើប្រាស់សេវាសុខភាព ។

## <u>២- ការគាំទ្រកម្ពុជារៀបចំខ្លួនឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច</u>

កម្ពុជារំពឹងថា នឹងត្រូវបានដាក់បញ្ចូលក្នុងបញ្ជីសម្រាប់ចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ក្នុង

ឆ្នាំ២០២១ ។ ដំណើរការនេះត្រូវការរយៈពេលយូរ ហើយការចាកចេញនេះអាចនឹងបញ្ចប់ជាស្ថាពរក្នុងរយៈពេល ៦ ឆ្នាំ ឬលើសពីនេះ ។ ដើម្បីធានាវឌ្ឍនភាពឆ្ពោះទៅការចាកចេញនេះ ពិសេសធានាចីរភាពក្នុងដំណាក់កាលអន្តរកាលបន្ទាប់ពីការចាកចេញ, ភាពជាដៃគូត្រូវផ្តោតសំខាន់ទៅលើការដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច (បង្ហាញក្នុងគំនូសតាងខាងក្រោម) ដែលរួមមាន÷ ក) ចំណូល, ខ) ការអភិវឌ្ឍធនធានមនុស្ស និង គ) ភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ។ លើមូលដ្ឋាននេះ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ត្រូវចាប់ផ្តើមរៀបចំ និងសម្របសម្រួលកិច្ចការនានាពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រអន្តរកាលនេះ ។

ក្នុងការត្រៀមខ្លួនសម្រាប់ដំណាក់កាលអន្តរកាលនេះ កម្ពុជាបន្តទទួលអត្ថប្រយោជន៍ជាច្រើនពីវិធានការពិសេសអន្តរជាតិ ពិសេសក្នុងវិស័យពាណិជ្ជកម្ម, កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍, និងជំនួយបច្ចេកទេស ។ ក្នុងន័យនេះ កម្ពុជាត្រូវទាញយកអត្ថប្រយោជន៍ឱ្យអស់លទ្ធភាពពីការប្រើប្រាស់វិធានការពិសេសទាំងនេះ ។ ការគាំទ្រដែលផ្តល់ឱ្យក្រុមប្រទេសមានការអភិវឌ្ឍតិចតួច រួមមាន÷

- **សមត្ថភាពខាងពាណិជ្ជកម្ម**: រួមមានភាពអនុគ្រោះក្នុងក្របខណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក, ភាពអនុគ្រោះជាឯកតោភាគី (Non-reciprocal preferential arrangements) និងការចូលរួមក្នុងក្របខណ្ឌពង្រឹងសមាហរណកម្មសម្រាប់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្ម (Enhanced Integrated Framework for Trade-Related TA) ។
- **កិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម**: ការគាំទ្រដល់បណ្តាប្រទេសមានការអភិវឌ្ឍតិចតួច ដើម្បីទទួលបាននូវអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ (ការអនុគ្រោះពន្ធ និងការមិនកំណត់កូតានាំចូល, និងបែបបទពន្ធគយសាមញ្ញ និងឆាប់រហ័ស) ក៏ដូចជាទទួលបាននូវការលើកលែងដោយផ្អែកលើអនុលោមភាព ។
- **ប្រព័ន្ធអនុគ្រោះស្តីពីវិធាននានាពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា និងការវិនិយោគ**: រួមមានវិធានការពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា និងការវិនិយោគ (TRIPS/TRIMS) ដែលអនុញ្ញាតឱ្យមានការបន្ធូរបន្ថយវិធាន និងការអនុវត្តនានាពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា និងការវិនិយោគ ក្នុងបណ្តាប្រទេសមានការអភិវឌ្ឍតិចតួចដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ។
- **កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍** : រួមមានការប្តេជ្ញារបស់ដៃគូអភិវឌ្ឍន៍ ក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព តាមរយៈការវិភាជធនធានរបស់ខ្លួន ចំនួន ០,១៥%-០,២០% នៃចំណូលជាតិសរុបសម្រាប់ផ្តល់ឱ្យប្រទេសមានការអភិវឌ្ឍតិចតួច ។
- **ជំនួយបច្ចេកទេស និងការគាំទ្រដទៃទៀត** : ដូចជា ធនាគារបច្ចេកវិទ្យារបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច, ការគាំទ្រផ្នែកប្រឹក្សាច្បាប់ និងការផ្តល់អាហារូបករណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក ។

## វឌ្ឍនភាពរបស់កម្ពុជាឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច




<u>ប្រភពទិន្នន័យ</u>: គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃ UNDESA

ប្រទេសមានការអភិវឌ្ឍតិចតួចក៏អាចទទួលការគាំទ្រពីកម្មវិធី “ផែនការសកម្មភាពសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច (LDC Program of Action) ដែលកំពុងអនុវត្តជំហានទី៤ របស់ខ្លួន ។ កម្មវិធីនេះត្រូវបានអនុម័តក្នុងឆ្នាំ២០១១ ហើយបានផ្តោតជាសំខាន់ទៅលើសមត្ថភាពផលិត និងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលរួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, មូលធនមនុស្ស និងសង្គម ។ កម្មវិធីនេះបានរួមបញ្ចូលនូវសកម្មភាពមួយចំនួនក្នុងវិស័យអាទិភាព ៨ គឺ ÷ សមត្ថភាពផលិត, កសិកម្ម, ពាណិជ្ជកម្ម, ផលិតផល, ការអភិវឌ្ឍសង្គម និងធនធានមនុស្ស, ការដោះស្រាយវិបត្តិ និងបញ្ហាប្រឈមថ្មីៗ, ការកៀរគរធនធាន និងអភិបាលកិច្ច ។

ការបន្តឋានៈរបស់កម្ពុជា ជាប្រទេសមានការអភិវឌ្ឍតិចតួច បានផ្តល់កាលានុវត្តភាពសម្រាប់លើកកម្ពស់សមត្ថភាពពាណិជ្ជកម្ម និងពន្លឿនការអនុវត្តគោលដៅអភិវឌ្ឍន៍ដែលមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។ ក្នុងន័យនេះ ការបន្តធ្វើការងារជាមួយដៃគូអភិវឌ្ឍន៍ក្នុងវិស័យពាណិជ្ជកម្ម និងដោយ

ពិគ្រោះយោបល់ ជាមួយតួអង្គក្នុងវិស័យឯកជន ពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា នឹងផ្តល់លទ្ធភាពឲ្យកម្ពុជាទាញយកអត្ថប្រយោជន៍កាន់តែច្រើនពីការអនុវត្តវិធានការពិសេសអន្តរជាតិទាំងនេះ ។

**៣- ហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍**

នៅកម្រិតសកល, ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពតម្រូវឲ្យមានហិរញ្ញប្បទានយ៉ាងច្រើនសន្ធឹកសន្ធាប់ (រាប់ទ្រីលាន មិនមែនពាន់លានដុល្លារ) ដើម្បីសម្រេចនូវចំណុចដៅប្រកបដោយមហិច្ឆតា នាឆ្នាំ២០៣០ ។ ការធ្វើមូលដ្ឋានីយកម្មនៃរបៀបវារៈស្តីពីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ នៅកម្ពុជា ក៏ទទួលស្គាល់អំពីភាពចាំបាច់ក្នុងការកៀរគរ និងគ្រប់គ្រងធនធានរបស់បណ្តាតួអង្គអភិវឌ្ឍន៍ ទាំងក្នុង និងក្រៅប្រទេស, ទាំងក្នុងវិស័យសាធារណៈ និងឯកជន ។ ក្នុងន័យនេះ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ គឺជាក្របខណ្ឌសំខាន់ សម្រាប់តម្រង់ទិសកិច្ចសហការជាមួយបណ្តាដៃគូអភិវឌ្ឍន៍, វិស័យឯកជន និងអង្គការសង្គមស៊ីវិល ព្រមទាំងជំរុញ និងលើកកម្ពស់តួនាទីនៃការបង្កើនលទ្ធភាពកៀរគរធនធាន និងតួនាទីជាកាតាលីករនៃហិរញ្ញប្បទានសហប្រតិបត្តិការ ពិសេសបន្តពង្រឹង និងពង្រីកភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ។

ទន្ទឹមនឹងនេះ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងគោលបំណងលើកកម្ពស់ស័ក្តិសិទ្ធិភាព, តម្លាភាព និងគណនេយ្យភាពនៃកិច្ចសហប្រតិបត្តិការនេះ ។ លើមូលដ្ឋាននេះ អង្គការមិនមែនរដ្ឋាភិបាលត្រូវបានលើកទឹកចិត្តឲ្យបន្តរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍ និងត្រូវបានចាត់ទុកជាតួអង្គសំខាន់ក្នុងដំណើរការពិគ្រោះយោបល់ តាមរយៈយន្តការក្រុមការងារបច្ចេកទេសចម្រុះ និងការរៀបចំ និងតាមដានការអនុវត្តសូចនាករតាមដានរួមគ្នា ។ ធនធានរបស់អង្គការទាំងនោះនឹងត្រូវបន្តកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអង្គការមិនមែនរដ្ឋាភិបាល សម្រាប់វិភាគ ហើយបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ នៅកម្ពុជា ។

សម្រាប់វិស័យឯកជន គោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាលស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន បានផ្តល់នូវក្របខណ្ឌបន្ថែម សម្រាប់ដៃគូអភិវឌ្ឍន៍សហការជាមួយរាជរដ្ឋាភិបាល និងវិស័យឯកជន ក្នុងទម្រង់ជាហិរញ្ញប្បទានចម្រុះ (Blended Finance Model) ។ ដៃគូអភិវឌ្ឍន៍ត្រូវបានលើកទឹកចិត្តឲ្យបន្តធ្វើសហហិរញ្ញប្បទានជាមួយវិស័យឯកជន ហើយ ក.អ.ក/គ.ជ.នា នឹងសិក្សាបន្ថែមអំពីបទពិសោធន៍ថ្មីៗក្នុងពេលពិគ្រោះយោបល់ទ្វេភាគី ដើម្បីតម្រង់ទិសការអនុវត្តភាពជាដៃគូថ្មីនេះ និងជំរុញការប្រើប្រាស់ទម្រង់នានាស្តីពីហិរញ្ញប្បទានចម្រុះនេះ ។

កិច្ចសហប្រតិបត្តិការត្បូង-ត្បូង បានលើកកម្ពស់ការផ្លាស់ប្តូរចំណេះដឹងផ្នែកគោលនយោបាយ, បច្ចេកវិទ្យា, ជំនាញ និងការអនុវត្ត រវាងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។ ការផ្លាស់ប្តូរចំណេះដឹងនេះត្រូវបានទទួលការស្វាគមន៍ ដោយសារបានបង្ហាញអំពីសាមគ្គីភាព, សមធម៌ និងការស្មើភាពគ្នាក្នុងកិច្ចសហប្រតិបត្តិការ ក៏ដូចជាស្ថានភាពប្រហាក់ប្រហែលគ្នារបស់ប្រទេសទាំងនេះ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រីកវិសាលភាពនៃទម្រង់សហប្រតិបត្តិការនេះ និងបន្តសហការជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀតដែលគាំទ្រអភិក្រមនេះ តាមរយៈកិច្ចសហប្រតិបត្តិការត្រីកោណ ។

ធនធានរបស់តួអង្គអភិវឌ្ឍន៍ទាំងអស់ មានតួនាទីសំខាន់ក្នុងការរួមចំណែកអនុវត្តឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍ជាតិ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងសមត្ថភាពកៀរគរ និងគ្រប់គ្រងភាពជាដៃគូទាំងនេះ ព្រមទាំងធ្វើបច្ចុប្បន្នភាពការព្យាករណ៍ហិរញ្ញប្បទាន ដែលមានចែងក្នុងឯកសារវាយតម្លៃស្ដីពីហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ឆ្នាំ២០១៧ ដើម្បីរៀបចំតម្រូវការហិរញ្ញប្បទានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

## VI. សន្និដ្ឋាន

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានកំណត់ចក្ខុវិស័យប្រកបដោយមហិច្ឆិតា សម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។ យុទ្ធសាស្ត្រនេះកំណត់វិស័យអាទិភាព និងសកម្មភាពមួយចំនួនដែលត្រូវអនុវត្តឱ្យបានសម្រេច ដើម្បីបង្កើតលក្ខណៈអំណោយផលក្នុងដំណាក់កាលអន្តរកាលសម្រាប់ឈានឆ្ពោះទៅអនុវត្ត “គំរូអភិវឌ្ឍសង្គម-សេដ្ឋកិច្ចថ្មី”មួយ ដែលបម្រើអត្ថប្រយោជន៍ប្រជាជន ។ ក្នុងបរិការណ៍នេះ យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ គឺជាក្របខណ្ឌសម្រាប់គ្រប់គ្រងភាពជាដៃគូ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ឈានទៅសម្រេចគោលដៅទាំងនេះ ។ យុទ្ធសាស្ត្រនេះបានកំណត់គោលការណ៍, យន្តការ និងឧបករណ៍សំខាន់ៗ ដើម្បីឱ្យការពិគ្រោះយោបល់បាន ÷ ក) ឯកភាពលើទិសដៅគោលនយោបាយ និងផែនការ, ខ) លើកកម្ពស់សមត្ថភាព និងពង្រឹងប្រព័ន្ធជាតិ និង គ) សម្រេចលទ្ធផលដែលអាចវាស់វែងបាន តាមរយៈប្រព័ន្ធតាមដាន និងវាយតម្លៃ ។

វឌ្ឍនភាពដ៏ត្រចះត្រចង់ និងក្នុងល្បឿនលឿន ដែលសម្រេចបានរហូតមកដល់បច្ចុប្បន្ន នឹងត្រូវបន្តពង្រឹង និងពង្រីកបន្ថែមទៀត តាមរយៈភាពជាអ្នកដឹកនាំដ៏រឹងមាំរបស់រាជរដ្ឋាភិបាល និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយធ្វើការក្នុងភាពជាដៃគូ ជាមួយភាគីពាក់ព័ន្ធ ។ ក្នុងន័យនេះ តួអង្គអភិវឌ្ឍន៍ទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យបន្តធ្វើការងារក្នុងន័យស្ថាបនា ជាមួយរាជរដ្ឋាភិបាល ស្របពេលដែលរាជរដ្ឋាភិបាលបន្តពង្រឹង និងបង្កើតយន្តការភាពជាដៃគូថ្មីៗ ដើម្បីកៀរគរ និងតម្រង់ទិសធនធាន សំដៅគាំទ្រដល់ការប្រែប្រួលថ្មីនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចក្នុងដំណាក់កាលបន្ទាប់ ។ ដើម្បីសម្រេចគោលដៅទាំងនេះ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ បានកំណត់នូវយន្តការភាពជាដៃគូជាក់លាក់មួយចំនួនដែលជំរុញកម្ពុជាឈានឆ្ពោះទៅសម្រេចបានជោគជ័យ និងវិបុលភាពបន្ថែមទៀត ក្នុងឋានៈជាប្រទេសចំណូលមធ្យម ។